# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៥-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៥៩ ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៦២៩

២៥-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦០ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា និងគ្រឿងឥស្សរិយយស ការពារជាតិ ចំពោះឯកឧត្តម ០៤ រូប ៧៦៣០

២៥-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦១ ស្តីពីការតម្លើងឋានៈជូនលោកជំទាវ និងឯកឧត្តម ចំនួន ០២ រូប ៧៦៣១

២៧-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦២ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ជូនឥស្សរជន ដែលមានស្នាដៃល្អ ក្នុងការបម្រើជាតិ មាតុភូមិ ចំនួន ០២ រូប ៧៦៣២

២៧-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦៣ ស្តីពីការតែងតាំងឯកឧត្តម **ហង្ស ទិចិត្រ** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម អនុប្រធានទី ១ រដ្ឋសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៦៣៣


## II_ក្រុមប្រឹក្សាធម្មនុញ្ញ


២៥-១១-២០០៦ -សេចក្តីសម្រេចលេខ ០៨៦/០១៣/២០០៦ កបធ.ច ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ៧៦៣៤

២៥-១១-២០០៦ -សេចក្តីសម្រេចលេខ ០៨៧/០១៤/២០០៦ កបធ.ច ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ៧៦៣៨


## III_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


២៧-១១-២០០៦ -អនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៦៤៥

២៨-១១-២០០៦ -អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្តីពីយថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល ៧៦៤៧

២៨-១១-២០០៦ -អនុក្រឹត្យលេខ ១៣២ អនក្រ.បក ស្តីពីការប្តូរឈ្មោះ និងដំឡើងឋានៈ វិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ ៧៦៥២

២៨-១១-២០០៦ -អនុក្រឹត្យលេខ ១៣៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៧៦៥៥

| | | |
|---|---|---|
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភារូបនីយកម្មសហគ្រាសសាធារណៈ | ៧៦៥៧ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ១៣៥ អនក្រ.បក ស្តីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន (ស្វាយរៀង) | ៧៦៥៩ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ១៣៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ៧៦៦២ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | ៧៦៦៤ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៧៦៦៧ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤២ អនក្រ.តត ស្តីពីការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ | ៧៦៦៩ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចមន្ត្រីរាជការ | ៧៦៧១ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៤ អនក្រ.តត ស្តីពីការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ | ៧៦៧៣ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៥ អនក្រ.តត ស្តីពីការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ | ៧៦៧៥ |
| ២៩-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៦ អនក្រ.តត ស្តីពីការសំរួល ផ្ទេរ និង ប្រគល់ភារកិច្ចមន្ត្រីរាជការ | ៧៦៧៧ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៧៦៧៩ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា | ៧៦៨០ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ៧៤៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៧៦៨១ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ៧៥០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ៧៦៨៣ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ៧៥១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ | ៧៦៨៤ |
| ៣០-១១-២០០៦ | -អនុក្រឹត្យលេខ ៧៥២ អនក្រ.តត ស្តីពីការដាក់ឱ្យនាយនគរបាលជាតិចូលនិវត្តន៍ | ៧៦៨៥ |


## ២_សេចក្តីសំរេច


| | | |
|---|---|---|
| ២៩-១១-២០០៦ | -សេចក្តីសំរេចលេខ ៥០ សសរ ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល | ៧៦៨៦ |
| ៣០-១១-២០០៦ | -សេចក្តីសំរេចលេខ ៥១ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្នាយ ខេត្តកំពង់ចាម | ៧៦៩០ |
| ៣០-១១-២០០៦ | -សេចក្តីសំរេចលេខ ៥២ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីត្រៀមរៀបចំកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍន៍ ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី ៣ | ៧៦៩២ |

## IV-ការិយាល័យកណ្តាលក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៩-១១-២០០៦ -ប្រកាសអន្តរក្រសួងលេខ ១២៤២ ប្រក.បទ.សហវ.ចមព ស្តីពីវិសោធនកម្មប្រការ ១១ នៃប្រកាសអន្តរក្រសួង ស្តីពីអាជ្ញាប័ណ្ណសេវាបញ្ជើឆាប់រហ័សអន្តរជាតិ ៧៦៩៦


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៩-១១-២០០៦ -ប្រកាសលេខ ១២៤៥សហ.ប្រក ស្តីពីការបង្កើតលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគណនេយ្យ ៧៦៩៨

២៩-១១-២០០៦ -ប្រកាសលេខ ១២៥២ សហវ.ប្រក ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការ ទីស្នាក់ការគយ និងរដ្ឋាករប្រចាំឃ្លាំង និងទីលានបញ្ចេញទំនិញពីគយ និងរដ្ឋាករ តិច ស៊្រុន អ៊ីមផត អិចផត និងត្រេនស្ពត (ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត តិច ស៊្រុន) ៧៧០៧

២៩-១១-២០០៦ -សារាចរណែនាំលេខ ០១១ សហវ ស្តីពីការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៦ ៧៧០៩


### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៣-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥២២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេរីបុត្រ អ៊ិនវេសមេន** ៧៧១៤

០៥-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥២៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ក្រោន ភ្នំពេញ ហ្គោល ខូ លីមីធីត** ៧៧១៦

០៥-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥២៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) គ្លូមិល ប៊ីស៊ីនីស ខូ អិលធីឌី** ៧៧១៨

០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៣០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស វ៉ាយ អេស អ៊ីម៉ិច អេន ត្រេនស្ព័ត** ៧៧២០

០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៣៦ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ុន ចេង អ៊ីមផត អិចផត** ៧៧២២

០៦-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៥៣៨ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.ធី.ធី ខនស្ត្រាក់សិន** ៧៧២៤

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រមុខរដ្ឋស្តីទី

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំង :

១-ឯកឧត្តម **គីម សោភ័ណ្ឌ** ជាជំនួយការសម្តេចប្រធានព្រឹទ្ធសភា បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២-ឯកឧត្តម **អ៊ួង សំគត់** ជាជំនួយការសម្តេចប្រធានព្រឹទ្ធសភា បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣៧.០៦១១.៤៩៥

លេខ : ៤៣០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជីនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៦០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

នូវ

-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១-ឧត្តមសេនីយ៍ឯក មាស សំអូល អត្តលេខ ០០០២១១

២-ឧត្តមសេនីយ៍ទោ ឆាន់ ចឡន: អត្តលេខ ០០៣៣៧២

-គ្រឿងឥស្សរិយយស ការពារជាតិ ថ្នាក់ សេនាជ័យសិទ្ធិ ចំពោះ :

៣-ឧត្តមសេនីយ៍ទោ ឡោត ហ៊ួរ អត្តលេខ ០១១០០៥

៤-ឧត្តមសេនីយ៍ទោ ចាប ភក្តី អត្តលេខ ០០០៤៣០

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៣រ៧.០៦១១.៤៩៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

លេខ : ៤៣១ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែវិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានតម្លើងឋានៈ ÷

១-លោកជំទាវ **តាន់ ធានី** បច្ចុប្បន្នអគ្គលេខាធិការ នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២-ឯកឧត្តម **យស់ អឿង** បច្ចុប្បន្នអគ្គលេខាធិការរង នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦
**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣រ៧.០៦១១.៤៩៧ លេខ: ៤៣៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៩ ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/១១០៦/៤៦២

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** បំពាក់គ្រឿងឥស្សរិយយស **សុវត្ថារា** តាមលំដាប់ ជូនឥស្សរជន ដែលមានស្នាដៃល្អ ក្នុងការបម្រើជាតិ មាតុភូមិ ដូចមានរាយនាមដូចខាងក្រោម :

**ក‧គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍**

-ឯកឧត្តម ឧត្តមសេនីយ៍ទោ **គង់ អឿង** ទីប្រឹក្សាផ្ទាល់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ខ‧គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

-លោកឧកញ៉ា **ម៉ៃ សេងឡុង**

**មាត្រា២:** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យ ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣៧៧.០៦១១.៤៩៤ លេខ: ៤៣៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម **ហង្ស ទិចិត្រ** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម អនុប្រធានទី១ រដ្ឋសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**ជា ស៊ីម**

៣រល.០៦១១.៤៨៩ លេខ : ៤៣២ ច.ល

**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៦
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ឌីនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១១៥/០១៥/២០០៦

ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ : ០៨៦/០១៣/២០០៦ កបធ.ច

ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់ឯកឧត្តម **គង់ គាំ** ប្រធានគណបក្សសម រង្ស៊ី ស្តីទី ផ្ទេរសិទ្ធិជូនលោក **ឌុច រិទ្ធី** ជាសមាជិកគណៈកម្មាធិការបោះឆ្នោតគណបក្សសម រង្ស៊ី

ដើម្បីជាតំណាងដាក់ពាក្យបណ្តឹង និង សវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញពាក្យបណ្តឹងរបស់លោក **ឌួច រិទ្ធី** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ប្តឹងទាមទារសុំឱ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន ៥.៤១៣ នាក់ចេញពីបញ្ជីបោះឆ្នោត និង បដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជំម្រះនៃ គ.ជ.ប ចុះហត្ថលេខាដោយឯកឧត្តម អ៊ឹម សួស្តី នាថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ១០:២៤ នាទី
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ សម្រេចបដិសេធពាក្យបណ្តឹងលេខ ០០១៨/០៦ ក.ទ.ជ.ប ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់លោក **ឌួច រិទ្ធី**
- បានឃើញលិខិតឧទ្ទេសនាមលេខ ៥១៧/០៦ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ចាត់តាំងសមាជិក និង មន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចូលរួមក្នុងសវនាការជំនុំជម្រះជាសាធារណៈ នៅក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុចុះស្រាវជ្រាវរបស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញ នៅឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង០៩គត់

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **ឌួច រិទ្ធី** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង។ ដូច្នេះយោងតាមមាត្រា ៤២ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ មាត្រា ៦៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា២៦នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ និង នៅក្នុងពាក្យបណ្តឹង លោក **ឌួច រិទ្ធី** បានបញ្ជាក់ថា លោកប្តឹងឱ្យលុបឈ្មោះជនជាតិវៀតណាម ចំនួន ៥.៤១៣ នាក់ ចេញពីបញ្ជីបោះឆ្នោត

- ដោយសំអាងលើរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីសញ្ជាតិ អនុក្រឹត្យលេខ ៣៦ អនក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៩៦ ហើយបានបញ្ជាក់ថា ជនទាំងនោះរស់នៅលើទូក និយាយភាសាវៀតណាម ខ្លះនិយាយខ្មែរមិនច្បាស់ មានត្រកូលមិនមែនខ្មែរ ដូចជា ង្វៀង យៀក ឡេ ដែលមិនមានលក្ខណៈសម្បត្តិទទួលសញ្ជាតិខ្មែរបានឡើយ។ លោកក៏បានបញ្ជាក់ដែរថា លោកមិនបានដឹងថា តើជនទាំងនោះមានអត្តសញ្ញាណប័ណ្ណ ឬ លិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀតទេ ព្រោះលោកពុំមានសិទ្ធិទៅសុំឆែកឆេរគេទេ
- យល់ឃើញថា នៅក្នុងសវនាការ និង ការសាកសួរយកចម្លើយ ឯកឧត្តម **មាន សទិ** និង ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់អំពីបញ្ហាមួយចំនួនទាក់ទងនឹងច្បាប់សញ្ជាតិ បញ្ហាជនជាតិ អនុសញ្ញាស្តីពីការបំបាត់ការរើសអើងជាតិសាសន៍ដែលប្រទេសយើងជាហត្ថលេខីមួយដែរនោះ។ ឯកឧត្តមក៏បានបញ្ជាក់ផងដែរថា នៅសវនាការ គ.ជ.ប លោក **ឌុច រិទ្ធី** គ្មានឯកសារអ្វីសំអាងក្រៅតែពីថា ជនទាំងនេះមានឈ្មោះ និង សំនៀងជាវៀតណាម។ ម៉្យាងទៀតឯកឧត្តមក៏បានអះអាងថា លោក **ចាប ស៊ុយ** មេឃុំព្រែកជ្រៃ និង ជាអតីតមេប៉ុស្តិ៍បានដឹង និង ស្គាល់ថា អ្នកទាំងនោះរស់នៅក្នុងឃុំតាំងពីឆ្នាំ១៩៧៩ និង បានបោះឆ្នោតតាំងពីឆ្នាំ១៩៩៣មក
- យល់ឃើញថា តាមការស្រាវជ្រាវរបស់តំណាងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នៅឯឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្តាល ប្រជាពលរដ្ឋចំនួន ៩.៤១៣នាក់ ដែលត្រូវសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង សុទ្ធតែមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ស្របតាមមាត្រា ៥៤ថ្មី ចំណុច "គ" នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ

## សម្រេច

### ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **ឌុច រិទ្ធី** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ដែលសម្រេចបដិសេធបណ្តឹងលេខ ០០១៨/០៦ ក.ទ.ជ.ប ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០០៦ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០០៦ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

**ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១១៦/០១៦/២០០៦

ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦

**សេចក្តីសម្រេច**

លេខ : ០៨៧/០១៤/២០០៦ កបធ.ច

ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើស-តាំងតំណាងរាស្ត្រ
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់ឯកឧត្តម **គង់ គាំ** ប្រធានគណបក្សសម រង្ស៊ី ស្តីទី ផ្ទេរសិទ្ធិជូនលោក **គីម សំណាង** ជាសមាជិកគណៈកម្មាធិការបោះឆ្នោតគណបក្ស

សម រង្ស៊ី ដើម្បីជាតំណាងដាក់ពាក្យបណ្តឹង និង ចូលរួមក្នុងសវនាការនៅក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញពាក្យបណ្តឹងរបស់លោក **ពឹម សំណាង** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ប្តឹងទាមទារលុបឈ្មោះជនជាតិវៀតណាមចេញពីបញ្ជីបោះឆ្នោត និង បដិសេធសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះហត្ថលេខាដោយឯកឧត្តម **អ៊ុម សូស្តី** នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ដែលអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ១៥:៤៩ នាទី
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ សម្រេចបដិសេធពាក្យបណ្តឹងលេខ ០០១០/០៦ ក.ទ.ជ.ប ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់លោក **ពឹម សំណាង**
- បានឃើញលិខិតលេខ ៩១៨/០៦ គ.ជ.ប ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ចាត់តាំងតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឱ្យចូលរួមក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញកំណត់ហេតុចុះស្រាវជ្រាវរបស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញនៅឃុំបាបោង ឃុំពាមរក៍ ឃុំអ្នកលឿង ឃុំព្រែកខ្សាយ(ក) ឃុំព្រែកខ្សាយ(ខ) ស្រុកពាមរក៍ ឃុំកំពង់លាវ ស្រុកកំពង់លាវ និង ឃុំកំពង់ប្រាសាទ ស្រុកពាមជរ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ១០ គត់

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **ពឹម សំណាង** ជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលបិទផ្សាយជាសាធារណៈបញ្ជីបោះឆ្នោតដំបូង។ដូច្នេះយោងតាមមាត្រា ៤២ ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ មាត្រា ៦៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ២៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ បណ្តឹងនេះក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ និង ក្នុងពាក្យបណ្តឹង លោក **ពឹម សំណាង** សុំប្តឹងឱ្យលុបឈ្មោះជនបរទេស ចំនួន ១.២៦៤នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅឃុំចំនួនប្រាំពីររបស់ខេត្តព្រៃវែង ដោយសំអាងថា ជនទាំងនោះគ្មានសញ្ជាតិខ្មែរ និយាយខ្មែរមិនច្បាស់ មិនចេះ

សរសេរអក្សរខ្មែរ រស់នៅតាមទូក តាមមាត់ទន្លេ ឬ ជួលផ្ទះគេនៅ ហើយប្រកាន់តាមទំនៀមទំលាប់វៀតណាម ។ លោកក៏បានអះអាងទៀតថា ជនទាំងនោះគ្មានលក្ខណៈសម្បត្តិអាចចូលសញ្ជាតិខ្មែរ តាមច្បាប់ស្តីពីសញ្ជាតិ ហើយក៏មិនអាចមានសិទ្ធិចុះឈ្មោះបោះឆ្នោតបានទេ បើអនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ។ លោកឆ្ងល់ទៀតថា ហេតុអ្វីជនខ្លះបានកាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បើជនទាំងនោះពុំទាន់មានព្រះរាជក្រឹត្យផ្តល់សញ្ជាតិផង ។ លោកក៏បានបន្ថែមទៀតថាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បើកសវនាការដោយមិនមានចុងចម្លើយ ។

- យល់ឃើញថា នៅក្នុងសវនាការជំនុំជម្រះ និង ក្នុងពេលសាកសួរចម្លើយ ឯកឧត្តម **ឯម សូផាត** និង ឯកឧត្តម **សោម ច័ន្ទឌីណា** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានបញ្ជាក់ថា នាសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លោក **គីម សំណាង** បានសំអាងត្រឹមតែថា ជនទាំងនោះមានឈ្មោះ និង ត្រកូលជាវៀតណាម ដោយគ្រាន់តែស្រង់យកឈ្មោះចេញពីបញ្ជីបោះឆ្នោត និង មិនបានបញ្ជាក់ពីឈ្មោះការិយាល័យនៃជនដែលត្រូវបានសុំលុបឈ្មោះ ។ ករណីឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង ក្រុមប្រឹក្សាឃុំ បានសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៤៦ នាក់ ក្នុងចំណោម ១៧២នាក់ ដែលត្រូវប្តឹងសុំឱ្យលុបឈ្មោះ ប៉ុន្តែក្នុងបណ្តឹងមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅឃើញឈ្មោះជនទាំងនោះនៅក្នុងបញ្ជីដែលសុំលុបឈ្មោះ ។ ឯកឧត្តម **ឯម សូផាត** ក៏បានបញ្ជាក់ផងដែរថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតគោរពតាម ច្បាប់ នីតិវិធី ហើយការលុបឈ្មោះត្រូវបង្ហាញភស្តុតាងត្រឹមត្រូវ និង ច្បាស់លាស់ ។ ការមិនបានចុះស្រាវជ្រាវដល់មូលដ្ឋាន ដោយសារគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានរចនាសម្ព័ន្ធនៅឯថ្នាក់ឃុំ និង ខេត្តហើយ ។ ប៉ុន្តែក្នុងសវនាការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏មានតំណាងរបស់ឃុំចូលរួម និង មានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំផងដែរ
- យល់ឃើញថា ថ្វីបើសវនាការនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពេលខ្លះមិនមានចុងចម្លើយចូលរួមក៏ដោយ ក៏គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចសម្រេចដោយកំបាំងមុខបានដែរ
- យល់ឃើញថា ឈ្មោះដែលបានប្តឹងឱ្យលុបចេញពីបញ្ជីបោះឆ្នោតជំបូង សុទ្ធតែមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ស្របតាមមាត្រា ៥៤ថ្មី ចំណុច "គ" នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា តាមការចុះស្រាវជ្រាវរបស់តំណាងក្រុមប្រឹក្សាធម្មនុញ្ញ បានរកឃើញថា ពលរដ្ឋចំនួន ៤៦នាក់ នៅឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង ត្រូវបានក្រុមប្រឹក្សាឃុំលុបចេញពីបញ្ជីបោះឆ្នោតដំបូង ដោយសារខ្លះស្លាប់ ខ្លះបានផ្លាស់ទីលំនៅ ហេតុនេះពលរដ្ឋទាំងនោះគួរលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដំបូង (ដូចក្នុងឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ)
- យល់ឃើញថា ការបញ្ជាក់អំពីធាតុពិតនៃអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ។

# សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់លោក **ពឹម សំណាង** ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និង បដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៦ ដែលសម្រេចបដិសេធបណ្តឹងលេខ ០០១០/០៦ គ.ជ.ប ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០០៦ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ.ក្រុមប្រឹក្សាជំនុំជម្រះ**

**ប្រធាន**

ជីវ គាំង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេច
លេខ ០៨៧/០១៣/២០០៦ កបធ.ច
ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០០៦

**ការិយាល័យលេខ ០៥២៨**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | លេខប័ណ្ណបន្ទាន់ដៃ | ផ្សេងៗ |
|---|---|---|---|---|---|
| ៤៣៣ | វៀង យ៉ាំងសឹង | ប្រុស | ១៩៥៥ | ៨.៨៦៣.២៩២ | |

**ការិយាល័យលេខ ០៥៣២**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | លេខប័ណ្ណបន្ទាន់ដៃ | ផ្សេងៗ |
|---|---|---|---|---|---|
| ៣៣៧ | វៀង ធីយី | ស្រី | ១៩៤០ | R ១.៦២៧.៦៣៨ | |
| ៣៣៨ | វៀង ធីលីង | ស្រី | ១៩៨១ | R ១.៦២៧.៦៣៥ | |
| ៣៣៩ | វៀង ធីវ៉ៃ | ស្រី | ១៩៨៣ | R ១.៦២៧.៦៣០ | |
| ៣៤០ | វៀង យ៉ាំងតឹង | ប្រុស | ១៩៨៥ | R ១.៦២៧.៦៣១ | |
| ៣៤១ | វៀង យ៉ាំងញឿ | ប្រុស | ១៩៨៣ | R ១.៦២៧.៦៣៩ | |
| ៣៤២ | វៀង យ៉ាំងតង | ប្រុស | ១៩៨៥ | R ១.៦២៧.៦៣២ | |

**ការិយាល័យលេខ ០៥៣៣**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | លេខប័ណ្ណបន្ទាន់ដៃ | ផ្សេងៗ |
|---|---|---|---|---|---|
| ៨១ | ចាំង យ៉ាំងអ៊ីង | ប្រុស | ១៩៧៧ | R ១.៦២៧.៧៨៥ | |
| ៩៥ | ជឿង យ៉ាំងភី | ប្រុស | ១៩៥៨ | ៨.៨៦៣.២១៥ | |
| ១១៧ | ដាង យ៉ាំងបេន | ប្រុស | ១៩៣៩ | R ១.៦២៧.៧៨០ | |

**ការិយាល័យលេខ ០៥៣៣**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | លេខប័ណ្ណបក្ខាន់ដៃ | ផ្សេងៗ |
|---|---|---|---|---|---|
| ១២២ | ឌិន ធីកើ | ស្រី | ១៩៥៦ | ៤.៥៧៨.៩៣១ | |
| ១២៥ | ឌិន ធីហឿង | ស្រី | ១៩៥៨ | ៤.៥៧៨.៩៩៤ | |
| ១២៨ | ឌិន យ៉ាំងវ៉ាង | ប្រុស | ១៩៤៩ | R ១.៦២៧.៧៧៨ | |
| ១៣៩ | ត្រឹង យ៉ាំងស៊ែ | ប្រុស | ១៩៦០ | ៤.៥៧៨.៩៥៤ | |
| ១៤០ | ត្រឹង យ៉ាំងហឿង | ប្រុស | ១៩២៥ | ៤.៥៧៨.៩៥៥ | |
| ១៤២ | ថាម ផល្លា | ស្រី | ១៩៧៣ | ៤.៥៧៨.០១៣ | |
| ១៦៩ | ទី ស្រេង | ប្រុស | ១៩៣៧ | ៤.៥៧៨.៨២៦ | |
| ២០០ | ផាម ហេងលី | ប្រុស | ១៩៥៣ | ៤.៥៧៨.៩៣៦ | |
| ២៥៨ | យ៉ ធីដូវ | ស្រី | ១៩៥០ | ៤.៥៧៨.០២៥ | |
| ២៦០ | យ៉ ធីហាយ | ស្រី | ១៩៥១ | ៤.៥៧៨.៩១៧ | |
| ២៧៤ | យី យ៉ាំងភុក | ប្រុស | ១៩៧៧ | R ១.៦២៧.៧០៦ | |
| ៣១៥ | វៀង ធីដាម | ស្រី | ១៩៦៥ | ៤.៥៧៨.៩៧៧ | |
| ៣១៧ | វៀង ធីតឿង | ស្រី | ១៩៥០ | ៤.៥៧៩.០៣៤ | |
| ៣២១ | វៀង ធីនៀក | ស្រី | ១៩៨៤ | R ១.៦២៧.៧៨៧ | |
| ៣២៤ | វៀង ធីលូ | ស្រី | ១៩៤៣ | ៤.៥៧៨.៩៣០ | |
| ៣២៨ | វៀង ធីឡាង | ស្រី | ១៩៦០ | ៤.៥៧៨.៩៣៧ | |
| ៣៣៥ | វៀង យ៉ាំងគី | ប្រុស | ១៩៨១ | R ១.៦២៧.៧៩៣ | |
| ៣៤៤ | វៀង យ៉ាំងប៊ិន | ប្រុស | ១៩៧៥ | ៤.៥៧៨.៩៨៥ | |
| ៣៤៥ | វៀង យ៉ាំងបៀន | ប្រុស | ១៩៨២ | R ១.៦២៧.៧៨៦ | |
| ៣៤៦ | វៀង យ៉ាំងប៉ាំង | ប្រុស | ១៩២៦ | R ១.៦២៧.៧០១ | |
| ៣៥០ | វៀង យ៉ាំងវ៉ាន់ | ប្រុស | ១៩២៨ | R ១.៦២៧.៧៨៣ | |
| ៣៥២ | វៀង យ៉ាំងវ៉ឹង | ប្រុស | ១៩៣៥ | ៤.៥៧៨.៩៧៩ | |
| ៤៦៩ | ឡេ យ៉ាំងដាង | ប្រុស | ១៩៨៥ | R ១.៦២៧.៧៨៤ | |

**ការិយាល័យលេខ ០៥៣៤**

| ល.រ | ឈ្មោះ | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | លេខប័ណ្ណបច្ចាស់ដៃ | ផ្សេងទៀត |
|---|---|---|---|---|---|
| ៣៨ | ង្វៀង យ៉ាំងកើន | ប្រុស | ១៩៥០ | R ១.៦២៧.៨៩១ | |
| ៣៩ | ង្វៀង យ៉ាំងហ៊ួ | ប្រុស | ១៩៤៨ | R ១.៦២៧.៨៩៧ | |
| ៥១ | ចាំង ធីណើ | ស្រី | ១៩៨០ | R ១.៦២៧.៩៤៤ | |
| ៥៤ | ចាំង ធីវ៉ា | ស្រី | ១៩៧៩ | R ១.៦២៧.៩៤៣ | |
| ៥៥ | ចាំង ធីស៊ីវ | ស្រី | ១៩៨២ | R ១.៦២៧.៩៤៥ | |
| ៦៨ | ជាម យ៉ាំងច្រុង | ប្រុស | ១៩៤៣ | R ១.៦២៧.៩១៣ | |
| ៧១ | ជឿង យ៉ាំងថវ | ប្រុស | ១៩៤០ | ៤.៩៧៩.៣៦៥ | |
| ១០៥ | ដូ យ៉ាំងសុខ | ប្រុស | ១៩៧៦ | R ១.៦២៧.៩០៤ | |
| ១៥៦ | ប៊ុយ ធីកឿង | ស្រី | ១៩៥៨ | R ១.៦២៧.៩០៣ | |
| ១៧២ | ផាម យ៉ាំងច្រុង | ប្រុស | ១៩៤៤ | R ១.៦២៧.៨៥៨ | |
| ២៦៣ | វិន យ៉ាំងហួន | ប្រុស | ១៩២៦ | R ១.៦២៧.៨៩៩ | |
| ២៦៥ | វៀង ធីជឹង | ស្រី | ១៩៤៧ | R ១.៦២៧.៨៩២ | |
| ៣៥២ | ឡេ ធីយ៉េ | ស្រី | ១៩៦១ | ៤.៩៧៩.២៥០ | |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៧០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៩ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣.៩៦៥ លានរៀល (បីពាន់ប្រាំបួនរយហុកសិបប្រាំលានរៀលគត់) ពីជំពូក ៣០ ( អន្តរាគមន៍មិនវិស័យសេដ្ឋកិច្ច ) មកជំពូក ១២ ( ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល ) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីផ្តល់ជូនអាជ្ញាធរអប្សរា សំរាប់ចំណាយរៀបចំប្រព័ន្ធអគ្គិសនីនៅក្បែរមជ្ឈមណ្ឌលពិព័រណ៍វប្បធម៌ពិភពលោកអង្គរ-យ៉ុងយូឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...១៣១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញក្រឹត្យលេខ ៩៧ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល ។

**មាត្រា ២.-**

យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ មានដូចខាងក្រោម :

ក- ផល អនុផលព្រៃឈើកែច្នៃ ឬមិនកែច្នៃគ្រប់ប្រភេទ ដែលប្រើប្រាស់វត្ថុធាតុដើមពីប្រភពព្រៃដាំ។ ឈើដើមកៅស៊ូ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក ។

ខ- ផល អនុផលព្រៃឈើដែលប្រើប្រាស់វត្ថុធាតុដើមស្របច្បាប់ពីប្រភពព្រៃធម្មជាតិដូចខាងក្រោម :

១- គ្រឿងសង្ហារឹម គ្រឿងផ្គុំសម្រាប់សង្ហារឹម និងគ្រឿងផ្គុំទូឯកសារ

២- ឈើគ្រឿងចម្លាក់ ឧបករណ៍ក្មេងលេង គ្រឿងតុបតែងលំអ គ្រឿងអនុស្សាវរីយ៍ គ្រឿងប្រដាប់ប្រដាការិយាល័យផលិតពីឈើ ឬអនុផលព្រៃឈើ គ្រប់ប្រភេទ និងផលិតផលដែលមានលក្ខណៈស្រដៀងគ្នា

៣- ឈើបាំកេ និងឈើការ៉ូក្រាល

៤- ឈើបាំឡែត និងឈើធ្វើឡាំង (ផ្គុំរួច ឬមិនទាន់ផ្គុំ)

៥- ឈើលាក់ ឬលកញ្ចឹឈ្នោល ឈើក្រឡឹង និងខាត់ គ្រោងទ្វារ-បង្អួច ឈើមានដំណាប់ ឬពន្លូញញ្ចឹឈ្នោល (ឈើធ្វើដងឧបករណ៍ប្រើប្រាស់)

៦- ផលិតផលឈើបិទការជាបន្ទះ ឬជាចំណិតភ្ជាប់គ្នា

៧- ក្តារធ្វើពីកំទេចឈើក្រោមសម្ពាធខ្លាំង និងក្តារបន្ទះ (កុងប្លាកេ)

៨- ឈើរនៀវ ឈើចិត ឈើច្បៀរជាសន្លឹក

៩- ឈើអារតាមខ្នាតទទឹងសាច់ឈើដែលមានកម្រាស់អតិបរមា១៩ស.ម ទោះបីនៅជាប់សំបកក៏ដោយ

១០- ឈើឈូសមុខ ២ ឬមុខ ៤ ព្រមទាំងមានខ្នាត និងគុណភាពនាំចេញ

១១- ចំណាំងកំទេចឈើ ម្សៅឈើ

១២- ឈើគួស ឈើចាក់ធ្មេញ ចង្កឹះ

១៣- ឈើកំណល់ផ្លូវរថភ្លើង (លើកលែងឈើប្រណិត)

១៤- ឈើជ្រុងដែលមានទោល ឬបន្ទារអតិបរមា ២៥ ស.ម ដែលបានសម្ងួតតាមលក្ខណៈធម្មជាតិ ឬក្នុងឡសម្ងួតតាមលក្ខណៈបច្ចេកទេស

១៥- ស៊ុមរូបវិចិត្រ ស៊ុមរូបថត ស៊ុមកញ្ចក់ ផ្ទាំងប្រដឹស ជើងទម្រផ្ទាំងប្រដឹស និងផលិតផលដែលមានលក្ខណៈស្រដៀងគ្នា

១៦-ផល អនុផលព្រៃឈើកែច្នៃមានលក្ខណៈប្រពៃណីរូមមាន :

ក- ផលិតផលមានចរិតសិល្បៈប្រពៃណីជាតិដូចជា ទូក ង ទូក មួង រទេះគោ រទេះក្របី រទេះសេះ រយាងដីរ

ខ-ឧបករណ៍ប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃដូចជា ស្នា ធ្នូ ត្បាល់ អង្រែ សង្រែក ជាល ល្អី ចង្អេរ កញ្ច្រែង កញ្ជើរ ហឹប ឈ្នាង ទ្រុងសត្វ ប្រអប់ដាក់គ្រឿងលោហៈធាតុ ប្រអប់ស្លា ម្លូ បារី គ្រឿងបណ្ណាការ ផលិតផលតម្បាញរុក្ខជាតិ ឈើច្រត់ ដំបងមូល ដំបងជ្រុង

គ-ឧបករណ៍ និងមធ្យោបាយបម្រើឱ្យផលិតកម្មកសិកម្មដូចជា នង្គ័ល រនាស់ ដងចប ដងកាំបិត ដងពូថៅ ស្នឹង ស្នៀត បង្កី

ឃ-ឧបករណ៍ និងមធ្យោបាយបម្រើឱ្យផលិតកម្មនេសាទដូចជា អង្រុត ឈ្នាង លប ទ្រូ បង្គោល ដងច្បូក ច្រវ៉ា ចែវ

ង- ឧបករណ៍តន្ត្រីដូចជា ស្គរ តាខេ រនាត ទ្រ ចាប៉ី ឃឹម

ច- ផលិតផល ដែលមានលក្ខណៈស្រដៀងគ្នា។

១៧- ក្តារបន្ទះឫស្សី គ្រឿងផ្គុំឫស្សី ផ្តៅ វល្លិ និង ផលិតផលដែលមានលក្ខណៈស្រដៀងគ្នា

១៨- ជ័រឈើ និង ផ្សិតព្រៃគ្រប់ប្រភេទ

១៩- ប្រេងចម្រាញ់ចេញពីផល អនុផលព្រៃឈើ

២០- ផលិតផលពីរុក្ខជាតិឱសថ ផលិតផលពីរុក្ខជាតិពុល ផលិតផលពីរុក្ខជាតិក្រអូប រុក្ខជាតិមានសារធាតុគីមីជីវៈ សារធាតុសម្លាប់ស្បែក

២១- ផលិតផលផ្កា ស្លឹក ផ្លែ រុក្ខជាតិព្រៃ

២២- ផល និងផលិតផលកែច្នៃពីអនុផលព្រៃឈើគ្រប់ប្រភេទ

២៣- ផលិតផលសត្វព្រៃកែច្នៃ ឬមិនកែច្នៃ និងសំណាកសត្វព្រៃក្នុងក្រុមប្រភេទមានដោយបង្គួរ។

**មាត្រា ៣.-**

យថាប្រភេទផល អនុផលព្រៃឈើ ដែលហាមនាំចេញមានដូចខាងក្រោម :

១- ឈើហ៊ុប ទោះបីបកសំបក ឬទាំងសំបក

២- ឈើអារសុទ្ធសាធ

៣- ឈើជ្រុង ដែលមានកម្រាស់លើសពី ២៥ ស.ម ទោះបីបានឈូសហើយក៏ដោយ

៤- ប្រេងម្រះព្រៅ វល្លិរមៀត និងម្សៅវល្លិរមៀត

៥- អុស និងធ្យូងឈើ ដែលមានប្រភពពីព្រៃធម្មជាតិ។

**មាត្រា ៤.-**

យថាប្រភេទផល អនុផលព្រៃឈើ ដែលអនុញ្ញាតឱ្យនាំចូលមានដូចខាងក្រោម :

ក- ឈើហ៊ុបមូល ឈើហ៊ុបជ្រុង ឈើអារ និង ផល អនុផលព្រៃឈើដទៃទៀត។

ខ- ផល អនុផលព្រៃឈើកែច្នៃ ។

**មាត្រា ៥.–**

ផល អនុផលព្រៃឈើដែលអនុញ្ញាតឱ្យនាំចេញ នាំចូល ត្រូវបង់ពន្ធជូនរដ្ឋតាមច្បាប់កំណត់ ។

**មាត្រា ៦.–**

ដូចមានចែងក្នុងមាត្រា ២ ចំណុច ខ វាក្យខ័ណ្ឌទី ១៦ នៃអនុក្រឹត្យនេះ :

ក-ការនាំចេញជាលក្ខណៈគ្រួសារ ឬទេសចរណ៍នូវផល អនុផលព្រៃឈើកែច្នៃ ដែលមានលក្ខណៈប្រពៃណី ពុំតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ និងលិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ ដែលចេញដោយប្រធានរដ្ឋបាលព្រៃឈើឡើយ ។

ខ-ការនាំចេញរបស់អតិថិជន ឬភាគីទីបីនូវផល អនុផលព្រៃឈើកែច្នៃដែលមានលក្ខណៈប្រពៃណី ក្នុងគោលដៅពាណិជ្ជកម្ម ពុំតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញឡើយ ប៉ុន្តែតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ ដែលចេញដោយប្រធានរដ្ឋបាលព្រៃឈើ ។

**មាត្រា ៧.–**

ការនាំចេញផល អនុផលព្រៃឈើដូចមានចែងក្នុងមាត្រា ២ ចាំបាច់ត្រូវមានអាជ្ញាប័ណ្ណនាំចេញ ដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន លើកលែងតែផលិតផល ដែលមានចែងក្នុងមាត្រា ២ ចំណុច ខ វាក្យខ័ណ្ឌទី ១៦ នៃអនុក្រឹត្យនេះ ។ ការពន្យារសុពលភាពនៃអាជ្ញាប័ណ្ណនាំចេញនេះ ត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៨.–**

ការនាំចូលផល អនុផលព្រៃឈើ ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតកម្មកែច្នៃក្នុងប្រទេស និង ផល អនុផលព្រៃឈើកែច្នៃគ្រប់ប្រភេទ ដែលបានកំណត់ក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ តម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចូលដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន និងមានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូល ដែលចេញដោយប្រធានរដ្ឋបាលព្រៃឈើ ។

**មាត្រា ៩.–**

ហាមដាច់ខាតការនាំចូលនូវប្រភេទរុក្ខជាតិព្រៃ ឬសត្វព្រៃដែលជាប្រភេទរាតត្បាត ឬធ្វើឱ្យប៉ះពាល់ដល់ធនធានសេនេទិចប្រភពកំណើត ។

**មាត្រា ១០.–**

អាស្រ័យតាមការចាំបាច់នៃតម្រូវការពាណិជ្ជកម្មក្នុងតំបន់ ឬអន្តរជាតិ ឬតាមតម្រូវការនៃសង្គម សេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលអាចអនុញ្ញាតឱ្យនាំចេញ នាំចូលនូវផល អនុផលព្រៃឈើដទៃទៀតបាន ។

**មាត្រា ១១.** –

យថាប្រភេទផល អនុផលព្រៃឈើ អាចអនុញ្ញាតឱ្យនាំចេញ នាំចូលបានតាមមាត់ច្រកទ្វារព្រំដែនស្របច្បាប់ ។

**មាត្រា ១២.**–

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.**–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-សាលាខេត្ត-ក្រុង

-សភាពាណិជ្ជកម្ម

-ដូចមាត្រា ១៣

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរឈ្មោះ និងដំឡើងឋានៈ វិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានប្តូរឈ្មោះ និង ដំឡើងឋានៈវិទ្យាស្ថានយោធាកម្ពុជា ទៅជាសាកលវិទ្យាល័យការពារជាតិ ហៅកាត់ជាភាសាខ្មែរ "ស.ក.ជ" ជាភាសាអង់គ្លេស "National Defense University" ហៅកាត់ជាភាសាអង់គ្លេស "N.D.U." ។ សាកលវិទ្យាល័យនេះ មានទីតាំងបច្ចុប្បន្ន នៅក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**មាត្រា ២.-**

សាកលវិទ្យាល័យការពារជាតិ មានតួនាទីជាអង្គភាពបណ្តុះបណ្តាលធនធានមនុស្ស លើវិស័យការពារជាតិ ស្រាវជ្រាវយុទ្ធសាស្ត្រ វិទ្យាសាស្ត្របច្ចេកទេសយោធា ភាសា និងចំណេះដឹងទូទៅ ដើម្បីលើកកម្ពស់គុណភាព សមត្ថភាព នាយទាហាននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីរាជការដែលមានការពាក់ព័ន្ធ លើវិស័យការពារជាតិ ។

**មាត្រា ៣.-**

សាកលវិទ្យាល័យការពារជាតិ មានឋានៈស្មើនឹងអគ្គនាយកដ្ឋាន និង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការពារជាតិ ។សាកលវិទ្យាល័យការពារជាតិ ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និងសាកលវិទ្យាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤.-**

សាកលវិទ្យាល័យការពារជាតិ ធ្វើការបណ្តុះបណ្តាលកម្រិត បរិញ្ញាប័ត្ររង បរិញ្ញាប័ត្រ បរិញ្ញាប័ត្រជាន់ខ្ពស់ និងបណ្ឌិត ។ សាកលវិទ្យាល័យការពារជាតិ ត្រូវរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត និងគ្រប់មុខជំនាញ ដោយមានការឯកភាពពីក្រសួងការពារជាតិ និងមានការទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥.-**

សាកលវិទ្យាល័យការពារជាតិ មានមហាវិទ្យាល័យចំនួន ប្រាំ (៥) ÷

១. មហាវិទ្យាល័យការពារជាតិ

២. មហាវិទ្យាល័យបញ្ជាការ-សេនាធិការ

៣. មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងភាសា

៤. មហាវិទ្យាល័យអប់រំចិត្តសាស្ត្រ និងស្រាវជ្រាវវិទ្យាសាស្ត្រយោធា

៥. មហាវិទ្យាល័យព័ត៌មានវិទ្យា និងភស្តុភារហិរញ្ញវត្ថុយោធា

ទៅអនាគត យោងតាមសេចក្តីត្រូវការចាំបាច់ក្នុងវិស័យការពារជាតិ សាកលវិទ្យាល័យនេះ អាចបើកសាខាមហាវិទ្យាល័យ ឬ មុខជំនាញដទៃទៀត ដោយអនុលោមតាមមាត្រា៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

លក្ខខណ្ឌជ្រើសរើសនិស្សិត ឱ្យចូលសិក្សានៅសាកលវិទ្យាល័យការពារជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ដោយសម្របសម្រួលទៅតាមបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការកំណត់លក្ខខណ្ឌ នៃការចូលរៀននៅឧត្តមសិក្សា និង ការណែនាំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ស្របតាមមាត្រា ២៩ និង មាត្រា ៣៦ នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**មាត្រា ៧.-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យការពារជាតិ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកម្រិត និងតាមមុខជំនាញដែលបានសិក្សា ។

សញ្ញាប័ត្រនេះ នឹងចុះហត្ថលេខាដោយសាកលវិទ្យាធិការ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

ក្រសួងការពារជាតិ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការក្នុងការរៀបចំកម្មវិធីសិក្សា និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន នៅសាកលវិទ្យាល័យការពារជាតិ តាមតម្រូវការ និង ភារកិច្ចកសាងធនធានមនុស្សលើវិស័យការពារជាតិ ។

**មាត្រា ៩.-**

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យការពារជាតិ និងអង្គភាពចំណុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និង សាកលវិទ្យាល័យការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) ជូនក្រសួងមហាផ្ទៃ-ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់បំណុលឆ្នាំ ២០០២-២០០៣ លើការផ្គត់ផ្គង់ឯកសណ្ឋានលក្ខណៈសញ្ញាសក្តិ និងគ្រឿងបន្ទាប់បន្សំនៃសំលៀកបំពាក់កងកំលាំងនគរបាលជាតិ ជូនក្រុមហ៊ុន **សោម សុផល** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី

## ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញសេចក្តីជូនដំណឹងលេខ ១៣១២ សជណ.សរ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០០៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣៨អនក្រចុះថ្ងៃទី១៩ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១ .-** អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រើប្រាស់គណនី "ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ" ដែលត្រូវបានបង្កើតឡើងតាមមាត្រា៨៣នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ផ្តល់ថវិកាបដិភាគជូនសាលាក្រុងភ្នំពេញ ចំណាយទិញដីបន្ថែមទំហំ ***៥.៣៣០,២៧ ម៉ែត្រការ៉េ*** សំរាប់ពង្រីកផ្លូវចូលទៅកាន់ទីលានចាក់សំរាមថ្មី នៃគំរោងគ្រប់គ្រងកាកសំណល់រឹង ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានតំលៃទឹកប្រាក់សរុប***៥៨.១៦៨,៩៦ ដុល្លារអាមេរិក*** ( ហាសិបប្រាំបីពាន់ មួយរយហុកសិបប្រាំបីដុល្លារអាមេរិក និងកៅសិបប្រាំមួយសេន ) ។

**មាត្រា ២ .-** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាលាក្រុងភ្នំពេញ និងប្រធានស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

***ចំលងជូន:***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន (ស្វាយរៀង)

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១

នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន (ស្វាយរៀង)** (MANHATTAN (SVAY RIENG) SEZ) ដែលមានទីតាំងស្ថិតនៅឃុំបាវិត និងឃុំបាទី ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន . (ស្វាយរៀង)** មានទំហំ មួយរយហាសិបប្រាំពីរហិកតា និងចិតសិបម៉ែត្រក្រឡា ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន (ស្វាយរៀង)** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តស្វាយរៀង និងក្រុមហ៊ុនមេនហាតធេន អ៊ិនធើរណេស្យូណល ខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តា

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៣៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១២៨ លានរៀល ( មួយរយម្ភៃប្រាំបីលានរៀលគត់ ) ពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) ជូនរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទូទាត់ការចំណាយកិច្ចប្រជុំបច្ចេកទេស និង កិច្ចប្រជុំប្រមុខមុខងារសាធារណៈអាស៊ាន នៃសន្និសីទអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈលើកទី ១៣ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងនាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/ ០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

-បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

## សម្រេច

**មាត្រា ១-**

ត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិចំណុះអគ្គនាយកដ្ឋានរដ្ឋបាល-កិច្ចការទូទៅ នៃក្រសួងទំនាក់ទំនងជាមួយ

រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បំពេញបន្ថែមឱ្យ អនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ២ -**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធានមួយ(០១)រូប និងអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និង ការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវកំណត់ដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ៣ -**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានភារកិច្ច ៖

-សម្របសម្រួល និង ទំនាក់ទំនងការងារជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និង អន្តរជាតិ និង ទីភ្នាក់ងារផ្តល់ជំនួយដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ការងារគ្រប់វិស័យរបស់ក្រសួង

-សម្របសម្រួល និង ទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-រៀបចំពិធីការសម្រាប់ថ្នាក់ដឹកនាំ កិច្ចប្រជុំនានា និងពិធីផ្សេងៗ របស់ក្រសួងជាមួយភ្ញៀវបរទេស

-សម្រួលលិខិតស្នាមដូចជា លិខិតឆ្លងដែន ទិដ្ឋាការ របស់មន្ត្រីរាជការក្រោមឱវាទក្រសួងដែលត្រូវទៅបំពេញបេសកកម្មនៅក្រៅប្រទេសតាមការចាត់តាំងរបស់ក្រសួង និងជនាញការបរទេស ដែលបំពេញការងារជាមួយក្រសួង

-ទទួលបន្ទុកកិច្ចការអាស៊ាន

-រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយអន្តរជាតិទៅលើវិស័យដែលពាក់ព័ន្ធជាមួយក្រសួងតាមគោលការណ៍ របស់រាជរដ្ឋាភិបាល

-រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិ សម្រាប់ចរចា និង ចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ

-តាមដាន និងវាយតម្លៃលើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យការបរទេស ដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ជូនថ្នាក់ដឹកនាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃសហប្រតិបត្តិការអន្តរជាតិ

-បូកសរុប វាយតម្លៃរាល់សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ដែលបានចុះពិធីសារ ជាមួយក្រសួង ហើយរាយការណ៍ពីលទ្ធផល នៃការងារទាំងនោះ ដោយសុំមតិកែសម្រួល ឬសុំបញ្ចប់កិច្ចព្រមព្រៀងណា ដែលអនុវត្តមិនបានត្រឹមត្រូវតាមគោលការណ៍កំណត់ ។

. នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធានមួយ ( ០១ ) រូប និង អនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅ របស់ការិយាល័យចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ៨-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ហ៊ុន សែន**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

**ម៉ែន សំអន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤១ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ឯក ម៉ូ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ជាអភិបាលរងខេត្តកំពង់ស្ពឺ ។

**មាត្រា ២ :** លោក **ឯក ម៉ូ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ៣ ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*(ដើម្បីជូនជ្រាប)*
*ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល និងប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **ខាវ អំណត់** មន្ត្រីក្របខ័ណ្ឌក្រសួងសាធារណៈការ និងដឹកជញ្ជូន ពីអភិបាលរងខេត្តកំពង់ឆ្នាំង អោយទៅបំរើការងារនៅក្របខ័ណ្ឌដើមវិញ ។

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **សួន រត្ន័សារាយ** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរងខេត្តកំពង់ឆ្នាំង ។

**មាត្រា ៣ :** លោក **សួន រត្ន័សារាយ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ១១ ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៥ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៧៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **ស៊ុម សុជាតិ** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៥ ជាអភិបាលរងខេត្តស្វាយរៀង ។

**មាត្រា ២ :** លោក **ស៊ុម សុជាតិ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ ;** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ស្លា ប្រយុទ្ធ** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ២ ពីអភិបាលរងទី១ ខេត្តរតនគីរី ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល

២- លោកស្រី **ដេង គឹម** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាលរងខេត្ត ខេត្តរតនគីរី ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- លោក **សូ នាក់** | ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ | | ជាអភិបាលរងទី១ ខេត្តរតនគីរី |
| ២- លោក **ស៊ីម ស៊ូយុទ** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៣ | ជាអភិបាលរងខេត្តរតនគីរី ។ |

**មាត្រា ៣ :** លោក **សូ នាក់** និងលោក **ស៊ឹម ស៊ូយុទ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ដោយឡែកលោក **សូ នាក់** ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*(ដើម្បីជូនជ្រាប)*
*ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **ងួ ស៊ីមយ៉ុន** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ពីអភិបាលរងខេត្តកោះកុង ឱ្យទៅបំរើការងារនៅក្របខ័ណ្ឌដើមវិញ ។

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក **សុន តារា** ឋានន្តរសក្តិ ក្រមការដើមខ្សែ ថ្នាក់លេខ ៩ ជាអភិបាលរងខេត្តកោះកុង

២- លោក **នង ឌីណាល់** មន្ត្រីក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ជាអភិបាលរងខេត្តកោះកុង ។

**មាត្រា ៣ :** លោក **សុន តារា** និងលោក **នង ឌីណាល់** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ដោយឡែកលោក **នង ឌីណាល់** ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**មាត្រា ៣** : ត្រូវបានប្រគល់ភារកិច្ចជូនលោក **សៅ ស្រស់** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរងខេត្តកំពង់ចាម ។

**មាត្រា ៤** : លោក **សៅ ស្រស់** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្ដីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៦ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការសំរួល ផ្ទេរ និងប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក **ថាវ គីមឡុង** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ពីអភិបាលរងទី១ខេត្តកំពង់ចាម អោយទៅបំរើការងារនៅក្របខ័ណ្ឌដើមវិញ ។

២- លោក **សៀក ជីវឡេង** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៣ ពីអភិបាលរងខេត្តកំពង់ចាម ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា ២ :** ត្រូវបានផ្ទេរភារកិច្ចលោក **ទុំ តិរច្ឆមុនី** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ពីអភិបាលរងខេត្តស្វាយរៀង ឱ្យទៅជាអភិបាលរងទី១ ខេត្តកំពង់ចាម ។

/…

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីជាសមាជិកក្រុមប្រឹក្សាភិបាលវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា ចំនួន១០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជាពិសេសលើផ្នែកសិក្សាស្រាវ ជ្រាវពូជស្រូវដែលអាចផ្តល់ទិន្នផលខ្ពស់ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក | **លាង សំហាត** | ប្រធានក្រុមប្រឹក្សាភិបាលអាណត្តិ ទី១ |
| ២-លោក | **សាន វណ្ណធី** | ប្រធានក្រុមប្រឹក្សាភិបាលអាណត្តិ ទី២ |
| ៣-ឯកឧត្តម | **ទ្រី ម៉េង** | សមាជិកក្រុមប្រឹក្សាភិបាល |
| ៤-លោក | **ចាប សុវណ្ណ** | សមាជិកក្រុមប្រឹក្សាភិបាល |
| ៥-លោក | **ស្រ៊ុន សុខុម** | សមាជិកក្រុមប្រឹក្សាភិបាល |
| ៦-លោក | **អេង គីមលី** | សមាជិកក្រុមប្រឹក្សាភិបាល |
| ៧-លោក | **កៅ ថុងហួ** | សមាជិកក្រុមប្រឹក្សាភិបាល |
| ៨-លោក | **ជា សុំណា** | សមាជិកក្រុមប្រឹក្សាភិបាល |
| ៩-លោក | **ជា សុផល** | សមាជិកក្រុមប្រឹក្សាភិបាល |
| ១០-លោក | **ស៊ុយ ស៊ុថុន** | សមាជិកក្រុមប្រឹក្សាភិបាល |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១២៤៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

៣៧៤

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ក្រោមឱវាទក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ិត** | **ណន្ទី** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២-ឯកឧត្តម | **គ៉ី** | **សារ៉ុន** | អគ្គនាយកនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣-ឯកឧត្តម | **ចាន់** | **ណរារិត** | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| ៤-លោក | **ម៉ែន** | **សារុម** | នាយកវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម កម្ពុជា |
| ៥-លោកស្រី | **ចាន់** | **ផលឈឿន** | នាយិការង វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម កម្ពុជា |

**ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :**

| | | | |
|---|---|---|---|
| ១-លោក | **អ៊ិត** | **ម៉ាការា** | នាយករងវិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្ម កម្ពុជា |
| ២-លោក | **សាយ** | **ពុទ្ធា** | ប្រធានការិយាល័យគ្រប់គ្រងស្ថានីយ៍ CARDI |
| ៣-លោក | **សេខ** | **វ៉ាង** | ប្រធានការិយាល័យវិទ្យាសាស្ត្រដី និងទឹក CARDI |
| ៤-លោក | **ឌី** | **ចាន់ណា** | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាល និង ព័ត៌មាន CARDI |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៧៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្តល់មេដាយការងារ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ក្រោមឱវាទក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ២០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក. មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-លោកបណ្ឌិត | **ព្រាប ទិសារៈនា** | ប្រធានការិយាល័យការពារដំណាំ CARDI |
| ២-លោក | **ហ៊ុន យ៉ាដាណា** | ប្រធានការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម CARDI |
| ៣-លោកស្រី | **សាខន សុផាន់** | ប្រធានការិយាល័យរុក្ខជម្រើសវិទ្យា CARDI |
| ៤-លោក | **ឈយ សំអុល** | ប្រធានការិយាល័យគណនេយ្យ និង ហិរញ្ញវត្ថុ CARDI |
| ៥-លោក | **គាំ វ៉ែម៊ត** | ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក CARDI |
| ៦-លោក | **ហ៊ិន សារិត** | អនុប្រធានការិយាល័យវិទ្យាសាស្ត្រដី និងទឹក CARDI |
| ៧-លោក | **អ៊ុំ សុគារព** | អនុប្រធានការិយាល័យក្សេត្រវិទ្យា និងប្រព័ន្ធ កសិកម្ម CARDI |
| ៨-លោក | **ពិត ខុនវ៉េអិល** | មន្ត្រីការិយាល័យជម្រើស វិទ្យា CARDI |
| ៩-លោក | **សាម ស៊ីរ៉ះម៉ែត** | មន្ត្រីការិយាល័យវិស្វកម្ម កសិកម្ម CARDI |
| ១០-លោក | **ជា សារ៉ែត** | មន្ត្រីការិយាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច សង្គម CARDI |
| ១១-លោក | **សោម ប៊ុណ្ណា** | អនុប្រធានការិយាល័យវិស្វកម្ម កសិកម្ម CARDI |
| ១២-លោកបណ្ឌិត | **គាង សុទ្ធី** | ប្រធានការិយាល័យវិទ្យាសាស្ត្រ និងប្រព័ន្ធ កសិកម្ម CARDI |

ខ_ មេដាយគ្រាក់ការងារ :

១-លោកស្រី ឪយ លីណា មន្ត្រីការិយាល័យនាយក CARDI

២-លោក ប៊ុល ចាន់ឌី មន្ត្រីការិយាល័យការពារដំណាំ CARDI

៣-លោក វេជ្ជ គឹមខុយ មន្ត្រីការិយាល័យក្សេត្រវិទ្យា និង ប្រព័ន្ធកសិកម្ម CARDI

៤-លោកស្រី ស៊ុខ សុខលី មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក CARDI

៥-លោក ឡេង ឡាយហួត មន្ត្រីការិយាល័យជម្រើសវិទ្យា CARDI

៦-លោក ទ័ន សារុំ មន្ត្រីការិយាល័យរដ្ឋបាល បុគ្គលិក CARDI

៧-លោក ឡោ ប៊ុណ្ណា អនុប្រធានការិយាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច-សង្គម CARDI

៨-លោក ខៀវ ប៊ុណ្ណារិទ្ធ អនុប្រធានការិយាល័យការពារដំណាំ CARDI

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី
១២

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអ្នកជំនាញការបរទេស ចំនួន ១១រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការជួយអភិវឌ្ឍន៍ វិស័យកសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-H.E. | Lisa Filipetto | Australian Ambassador |
| ២-Mr. | Blair Exell | Former Ist Secretary of Australian Ambassy |
| ៣-Mr. | Fleur Davies | Former Ist Secretary of Australian Ambassy |
| ៤-Mr. | Rian Dixon | Aus AID Representative |
| ៥-Dr. | Peter Core | Director of ACIAR, Australia |
| ៦-Dr. | Jonh Skerritt | Deputy Director of ACIAR, Australia |
| ៧-Prof. | Shu Fukai | Prof. from University Queensland |
| ៨-Dr. | Ronal Cantrel | Former Director General of IRRI |
| ៩-Dr. | M.S Swaminathan | Former Director General of IRRI |
| ១០-Dr. | Jung-Chaee Keng | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ឆុន ណាំ នៃសាធារណរដ្ឋកូរ៉េ |
| ១១-Dr. | Ja-Ock Guh | សាស្ត្រាចារ្យ និង អតីតព្រឹទ្ធសាស្ត្រាចារ្យ មហាវិទ្យាល័យកសិកម្ម និងវិទ្យាសាស្ត្រជីវិត នៃសាកលវិទ្យាល័យ ឆុន ណាំ នៃសាធារណរដ្ឋកូរ៉េ ។ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..១៧៥១..អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្ដូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ស្ដីពីការបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម :

១- លោក ផុន សេខ ឱ្យបំពេញមុខងារជាព្រឹទ្ធបុរស មហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ

២- លោកស្រី អ៊ុំ រ៉ាទី ឱ្យបំពេញមុខងារជានាយិកាមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៧៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការដាក់អោយនាយនគរបាលជាតិចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញក្រឹត្យលេខ ១០ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មចំពោះនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា ១** : ត្រូវបានដាក់អោយចូលនិវត្តន៍ នាយនគរបាលជាតិជាន់ខ្ពស់ថ្នាក់វរសេនីយ៍ឯកចំនួន **០៥រូប** នៃក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោម :

១- វរសេនីយ៍ឯក **អ៊ឹម សារ៉ាន** អត្តលេខ ០៣២១ អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន
២- វរសេនីយ៍ឯក **អ៊ិន សារិន** អត្តលេខ ០៣២៩ អនុប្រធាននាយកដ្ឋាននគរបាលអន្តរជាតិ
៣- វរសេនីយ៍ឯក **សេក យឹម** អត្តលេខ ០២៧២ អនុប្រធាននាយកដ្ឋានផ្សព្វផ្សាយអប់រំ
៤- វរសេនីយ៍ឯក **ខិន ឧន់** អត្តលេខ ០២០៦ អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់
៥- វរសេនីយ៍ឯក **ហែម គ្រីស្នា** អត្តលេខ ០២៥៨ អនុប្រធាននាយកដ្ឋានអង្គរក្ស ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែវិច្ឆិកា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចំលងជូន</u> :

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥០ អនក្រ

# សេចក្តីសំរេច

## ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ំ រេ ច

**ប្រការ១ :** កំណត់របៀបរបបការងារ និងបែងចែកភារកិច្ច ជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេស សំដៅធានាការអនុវត្តនីច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ។

**ប្រការ២ :** ចំពោះនាយករដ្ឋមន្ត្រី : **សម្តេច ហ៊ុន សែន** : នាយករដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំរួមការងាររបស់គណៈរដ្ឋមន្ត្រី ចាត់ចែងបញ្ហារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ និងទទួលផ្ទាល់លើការងារគ្រប់គ្រងគ្រោះមហន្តរាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ៣ :** ចំពោះឧបនាយករដ្ឋមន្ត្រី :

១- ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការដោះស្រាយការងារប្រចាំថ្ងៃ ជានាយករដ្ឋមន្ត្រីស្តីទី ពេលអវត្តមាននាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើកិច្ចការសន្តិសុខជាតិ ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជួញដូរមនុស្ស ដឹកនាំប្រតិបត្តិការទប់ស្កាត់ និងប្រឆាំងភេរវកម្ម ដឹកនាំកិច្ចការវិមជ្ឈការ និងសហវិមជ្ឈការ គាំទ្រកម្មវិធីសីលា ការកែទម្រង់ ការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ ។ ជាមួយនេះជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងផែនការ ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

២- ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសម្របសម្រួលកិច្ចការ សំរាប់គណៈរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី និងបណ្តាឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារតាមដានសម្របសម្រួល និងដឹកនាំកិច្ចការកែទម្រង់រដ្ឋ ដំណើរការតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ការងារបំផ្លាញមីន និងជួយជនពិការដោយសារមីន និងព័ត៌មានវិទ្យា ។ ជួយនាយករដ្ឋមន្ត្រី ក្នុងការរៀបចំចម្លើយតបនឹងសំណួររបស់សមាជិករដ្ឋសភា តាមនីតិវិធីដូចមានចែងក្នុងមាត្រា ៩៦ នៃរដ្ឋធម្មនុញ្ញ ។ ជាមួយនេះជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដឹកនាំអាជ្ញាធរជាតិប្រេងកាតកម្ពុជា និង អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។

៣- ឯកឧត្តម **លឺ ឡាយស្រេង** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងអភិវឌ្ឍន៍ជនបទ ។

៤- ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើការងារការពារជាតិ ទទួលសិទ្ធិពីនាយករដ្ឋមន្ត្រី ក្នុងការងារគ្រប់គ្រង និងបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។ ជាមួយនេះជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

៥- ឯកឧត្តម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី លើការងារការបរទេស និងសហប្រតិបត្តិការអន្តរជាតិទូទៅ ។ ជាមួយនេះ ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួលគ្រប់គ្រងក្រសួងពាណិជ្ជកម្ម និងគណៈកម្មាធិការជាតិទន្លេមេគង្គ ។

៦- ឯកឧត្តម **ញ៉ឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម និងជួយឯកឧត្តម **ទៀ បាញ់** ក្នុងការងារគ្រប់គ្រង និងបញ្ជាកងរាជអាវុធហត្ថលើផ្ទៃប្រទេស ។ ទន្ទឹមនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ញ៉ឹក ប៊ុនឆៃ** ជួយនាយករដ្ឋមន្ត្រី លើការងារសម្របសម្រួលគ្រប់គ្រងក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ញ៉ឹក ប៊ុនឆៃ** ដឹកនាំគណៈកម្មាធិការជាតិ ដើម្បីប្រជាជន និងការអភិវឌ្ឍន៍ គណៈកម្មការត្រួតពិនិត្យដោះស្រាយបាតុភាព និងអភិវឌ្ឍន៍ នៅតាមបណ្តោយព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង ចំណុះឱ្យអាជ្ញាធរជាតិទទួលបន្ទុក កិច្ចការព្រំដែន និងកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី ។

៧- ឯកឧត្តម **កែវ ពុទ្ធរស្មី** ឧបនាយករដ្ឋមន្ត្រី ជួយនាយករដ្ឋមន្ត្រី ក្នុងការងារសម្របសម្រួល និងគ្រប់គ្រងក្រសួងកិច្ចការនារី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងធម្មការ និង កិច្ចការសាសនា និង កិច្ចការមួយចំនួនទៀត តាមការប្រគល់ភារកិច្ចពីនាយករដ្ឋមន្ត្រី ។

**ប្រការ៤ :** នាយករដ្ឋមន្ត្រី និង ឧបនាយករដ្ឋមន្ត្រី ជាគណៈអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី ដែលត្រូវប្រជុំពិគ្រោះការងារតាមការកោះអញ្ជើញពីនាយករដ្ឋមន្ត្រី ឬពីនាយករដ្ឋមន្ត្រីស្តីទី ។

**ប្រការ៥ :** ឧបនាយករដ្ឋមន្ត្រីទទួលអនុវត្តការងារ ឬបេសកកម្មផ្សេងទៀត ដែលនាយករដ្ឋមន្ត្រីប្រគល់ជូន ស្របតាមមាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

**ប្រការ៦ :** ឧបនាយករដ្ឋមន្ត្រី ០១ រូបៗមានទីប្រឹក្សា ០៤ រូប ក្នុងនោះ ០២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ ០២ រូប មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងជំនួយការ ០៣ រូប ក្នុងនោះ ០១ រូប មានឋានៈស្មើ អគ្គនាយក ០១ រូប មានឋានៈស្មើ អគ្គនាយករង និង ០១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ៧ :** ចំពោះទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស :

១- ព្រះអង្គម្ចាស់ក្សត្រិយ៍ **នរោត្តម ម៉ារី រណឫទ្ធិ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរអេដស៍

២. ឯកឧត្តម **យី តាំងលីម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជារដ្ឋមន្ត្រីអមមហាអនុតំបន់ទន្លេមេគង្គ

៣- ឯកឧត្តម **វេង សិរីវុឌ្ឍ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិទេសចរណ៍កម្ពុជា និងជាប្រធានក្រុមការងារទេសចរណ៍ សំរាប់កាត់បន្ថយភាពក្រីក្រ

៤- ឯកឧត្តម **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ១ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

៥- ឯកឧត្តម **តាវ សេងហួរ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

៦- ឯកឧត្តម **លី ធុច** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជាអនុប្រធានទី ២ នៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**ប្រការ៨ :** ទេសរដ្ឋមន្ត្រី ទទួលអនុវត្តបន្ថែមនូវការងារផ្សេងទៀត ដែលនាយករដ្ឋមន្ត្រី ប្រគល់ជូន ។

**ប្រការ៩ :** ទេសរដ្ឋមន្ត្រី ដែលទទួលបន្ទុកបេសកកម្មពិសេសមានជំនួយការ ០២ រូប ក្នុងនោះ ០១ រូប មានឋានៈស្មើអគ្គនាយករង និង ០១ រូប មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**ប្រការ១០:** នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២-៣-៧-១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៥៦ សសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្នាយ ខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ ១**: បង្កើតគណៈកម្មការចំរុះ ដើម្បីសិក្សាអំពីរបៀបចាក់លុបផ្ទៃដីបឹងស្នាយខេត្តកំពង់ចាម ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣-ឯកឧត្តម **ហ៊ុន ណេង** | អភិបាលខេត្តកំពង់ចាម | អនុប្រធានអចិន្ត្រៃយ៍ |

| | | | |
|---|---|---|---|
| ៤-ឯកឧត្តម | **ម៉ិន អ៊ុយ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-ឯកឧត្តម | **អ៊ិត ប្រាំង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧-ឯកឧត្តម | **សំ សារិត** | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៨-ឯកឧត្តម | **សួន ហេង** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៩-ឯកឧត្តម | **នូ គៀង** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១០-ឯកឧត្តម | **ឆា ជុប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |

**ប្រការ ២** : គណៈកម្មការចំរុះនេះ មានភារកិច្ចសិក្សាបន្ថែមអំពីរបៀបចាក់លុបផ្ទៃដីបឹងស្ពាយ ដោយធានាដោះស្រាយការបាត់ផ្ទៃរងទឹកភ្លៀង ទីតាំងប្រភពដីដែលត្រូវបូមចាក់លុបបឹង និងអំពីការទូទាត់ចំណាយជាក់ស្តែង ដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

**ប្រការ ៣** : អនុប្រធាន និងសមាជិកគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំ និងចូលរួមបំពេញភារកិច្ចតាមការអញ្ជើញ និងតាមការណែនាំរបស់ប្រធាន ។

**ប្រការ ៤** : គណៈកម្មការចំរុះនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្នុងករណីចាំបាច់គណៈកម្មការចំរុះនេះ អាចបង្កើតអនុគណៈកម្មការ ឬក្រុមការងារជំនាញដើម្បីជួយក្នុងកិច្ចការសិក្សាបន្ថែមនេះ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧ ស.ស.រ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីត្រៀមរៀបចំ កិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍន៍ ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ១ :**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | **ឆ័យ ធឿន** | អគ្គលេខាធិការរង រាជរដ្ឋាភិបាលកម្ពុជា | សមាជិក |
| ៤-ឯកឧត្តម | **សក់ សេដ្ឋា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-ឧត្តមសេនីយ៍ឯក | **ម៉ៅ ច័ន្ទតារា** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៦-ឧត្តមសេនីយ៍ឯក | **ឈុំ សុជាតិ** | មេបញ្ជាការទីចាត់ការព្រំដែន អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៧-ឯកឧត្តម | **ដាវ សារី** | អ្នកបកប្រែភាសាវៀតណាម | សមាជិក |
| ៨-ឧត្តមសេនីយ៍ឯក | **ចាន់ អ៊ាន** | ប្រធាននាយកដ្ឋានកណ្តាលព្រំដែន នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ៩-ឧត្តមសេនីយ៍ទោ | **ថោង លីម** | ប្រធាននាយកដ្ឋានជនបរទេស នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១០-ឧត្តមសេនីយ៍ត្រី | **វ៉ន ឈុនលី** | ប្រធាននាយកដ្ឋានព្រំដែនទឹក នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១១-ឧត្តមសេនីយ៍ត្រី | **ញាណ វិបុល** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | សមាជិក |

**ប្រការ២ :**

គណៈកម្មការខាងលើនេះ មានភារកិច្ចដូចខាងក្រោម ÷

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំខ្លឹមសារ សំរាប់គណៈប្រតិភូដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចូលរួមក្នុងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកលើខ្លឹមសារដែលបានសម្របសម្រួលខាងលើនេះ ដើម្បីពិភាក្សាជាមួយភាគីវៀតណាម សហការរៀបចំខ្លឹមសារប្រជុំអោយបានសមស្រប ។

**ប្រការ៣ :**

- ប្រធានគណៈកម្មការត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អនុប្រធាន និង សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និង ទទួលភារកិច្ចតាមការចាត់ចែង របស់ប្រធានគណៈកម្មការ
- គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រា និង ប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃ ក្នុងការចាត់ចែងការងាររបស់ខ្លួន ។

**ប្រការ៤ :**

ក្នុងការសំរបសំរួលខ្លឹមសារនៃកិច្ចប្រជុំ គណៈកម្មការមានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធចូលរួមតាមការចាំបាច់។

**ប្រការ៥ :**

គណៈកម្មការត្រូវបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍន៍ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម លើកទី៣ ត្រូវបានបញ្ចប់រួចរាល់និងបន្ទាប់ពីបានធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា នៃរាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និង ឯកឧត្តម អស់លោក ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦ " ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

vn3b1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ ......ប្រក.បទ.សហវ.ចមព

"...ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព"

# ប្រកាសអន្តរក្រសួង
# ស្តីពី
# វិសោធនកម្មប្រការ១១ នៃប្រកាសអន្តរក្រសួងស្តីពី អាជ្ញាប័ណ្ណសេវាបញ្ជើឆាប់រហ័សអន្តរជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ សហវ.ម ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០២ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរជ្ជទេយ្យចំណូល
- បានឃើញប្រកាសអន្តរក្រសួងលេខ១១២០ប្រក.បទ.សហវ.ចមព ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាជ្ញាប័ណ្ណសេវាបញ្ជើឆាប់រហ័សអន្តរជាតិ
- យោងសំណើឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៦។

## ស ម្រេ ច

**ប្រការមួយ:** ប្រការ ១១ នៃប្រកាសអន្តរក្រសួង លេខ១១២០ប្រក.បទ.សហវ.ចមព ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាជ្ញាប័ណ្ណសេវាបញ្ជើឆាប់រហ័សអន្តរជាតិ ត្រូវបានកែប្រែ ដូចខាងក្រោម :

**ប្រការ១១ថ្មី:** តម្លៃអាជ្ញាប័ណ្ណសេវាបញ្ជើឆាប់រហ័សអន្តរជាតិ ត្រូវបានកំណត់ ៤.២០០.០០០រៀល ក្នុង ១ឆ្នាំ។

អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណត្រូវបង់ប្រាក់កក់ចំនួន ១.០០០.០០០រៀល នៅពេលដាក់ពាក្យសុំដំបូង និងបង់បង្គ្រប់នៅពេលទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ក្នុងករណីស្នើសុំអាជ្ញាប័ណ្ណ ពុំទទួលបានការអនុញ្ញាត ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ប្រាក់កក់ដំបូងចំនួន ១.០០០.០០០រៀល ត្រូវប្រគល់ជូនអ្នកស្នើសុំវិញ។

ក្នុងករណីអ្នកដាក់ពាក្យបានបោះបង់ចោលការស្នើសុំអាជ្ញាប័ណ្ណ ក្រោយពេលគោលការណ៍ ត្រូវបានអនុញ្ញាតពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ប្រាក់កក់ចំនួន ១.០០០.០០០រៀល ត្រូវបង្វែរចូលថវិកាជាតិ។

**ប្រការ ពីរ:** អគ្គនាយកដ្ឋាន នាយកដ្ឋាន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

សូ-ឃុន

កន្លែងចម្លង:
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ទីស្តីការគណៈរដ្ឋមន្ត្រី
អាជ្ញាធរសវនកម្មជាតិ
គ្រប់សាលាខេត្តក្រុង
"ដើម្បីជូនជ្រាប"
ដូចប្រការ ពីរ
"ដើម្បីមុខការ"
ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១២៤៥ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០០៦

# ប្រកាស

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគណនេយ្យ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤ស្តីពីការបំពេញបន្ថែម និងការកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ

-បានឃើញអនុក្រឹត្យលេខ ០៨/ អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ១៧០សហវ ចុះថ្ងៃ២៧ ខែមីនា ឆ្នាំ២០០៣ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល ប្រចាំក្រុមប្រឹក្សាជាតិគណនេយ្យ អាណត្តិទី០១

-បានឃើញកំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៦

-យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច :

## ជំពូកទី១

## អំពីបទប្បញ្ញត្តិទូទៅ

**ប្រការ១ :**

បង្កើតអង្គភាពមួយឈ្មោះថា " **លេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគណនេយ្យ** " ដែលតទៅនេះ ហៅកាត់ថា " **លេខាធិការដ្ឋានក្រុមប្រឹក្សា** " អោយធ្វើជាសេនាធិការរដ្ឋបាលអចិន្ត្រៃយ៍ ដោយអនុលោមតាម មាត្រា១១ នៃអនុក្រឹត្យលេខ០៨អនក្រ-បក ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលសរសេរកាត់ "ក.ជ.គ." ដើម្បីធានា ដំណើរការប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាពនៃក្រុមប្រឹក្សានេះ។

## ជំពូកទី២

## អំពីរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានក្រុមប្រឹក្សា

**ប្រការ២ :**

ដូចមាននៅក្នុងអង្គការលេខរបស់ក.ជ.គ.ជាឧបសម្ព័ន្ធ រចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានក្រុមប្រឹក្សា ត្រូវបានរៀបចំអោយមានការិយាល័យចំនួន៣ នៅក្រោមឱវាទ ដូចខាងក្រោម :

១-ការិយាល័យរដ្ឋបាលនិងទំនាក់ទំនងសាធារណៈ

២-ការិយាល័យបញ្ញត្តិកម្មនិងត្រួតពិនិត្យ

៣-ការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ។

ប៉ុន្តែក្នុងពេលអនាគត ប្រសិនបើការរីកចំរើននៃសកម្មភាពរបស់ខ្លួនតម្រូវ ក.ជ.គ.ក៏អាចនឹងស្នើសុំអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបើកទូលាយថែម នូវរចនាសម្ព័ន្ធនេះ ដោយបង្កើតផ្នែកពីរឬច្រើនជាង នៅក្រោមឱវាទការិយាល័យនិមួយៗខាងលើ និងស្នើអោយតែងតាំងមន្ត្រីទទួលបន្ទុក តាមការជាក់ស្តែង។

មុខងារ-ភារកិច្ចរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានិងការិយាល័យក្រោមឱវាទត្រូវបានកំណត់ នៅជំពូកទី៣ នៃប្រកាសនេះ ។

**ប្រការ៣ :**

ដើម្បីធានាការអនុវត្តន៍ត្រឹមត្រូវតាមស្តង់ដារគណនេយ្យនិងស្តង់ដារសវនកម្មកម្ពុជា បន្ទាប់ពីប្រកាសនេះចូលជាធរមាន ក.ជ.គត្រូវបានអនុញ្ញាតអោយបង្កើតអង្គភាពជំនួយមួយឈ្មោះថា "**គណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិគណនេយ្យឱ្យធ្វើជាសេនាធិការបច្ចេកទេស**" នៅអមលេខាធិការដ្ឋានក្រុមប្រឹក្សា និងក្នុងករណីចាំបាច់នូវអនុគណៈកម្មការបច្ចេកទេស សំរាប់មួយដងមួយកាលតាមមុខជំនាញ ដោយអនុលោមតាមមាត្រា៨ នៃអនុក្រឹត្យដែលយោងនៅប្រការ១ ខាងលើ ។

**ប្រការ៤ :**

លេខាធិការដ្ឋានក្រុមប្រឹក្សាត្រូវដឹកនាំដោយលេខាធិការមួយរូប អមដោយលេខាធិការរងមួយ ឬច្រើនរូបដែលត្រូវតែជាមន្ត្រីក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន អោយជួយធ្វើការតាមការចាំបាច់ ។

មុខតំណែងជាលេខាធិការមានវិសមិតភាពជាមួយមន្ត្រីក្របខ័ណ្ឌនៃមុខងារសាធារណៈ ឬវិជ្ជាជីវៈឯកជនដែលកំពុងអនុវត្តការងារគណនេយ្យ ។

លេខាធិការនិងលេខាធិការរងត្រូវតែងតាំងឬផ្លាស់ប្តូរ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក.ជ.គ. ក្រោយពីបានពិគ្រោះយោបល់ដោយសម្លេងភាគច្រើន ដោយអនុលោមតាមមាត្រា១១នៃអនុក្រឹត្យដែលយោងនៅប្រការ១ខាងលើដូចគ្នា ។

លេខាធិការរងជំនួសលេខាធិការ នៅពេលមន្ត្រីរូបនេះអវត្តមាន ប៉ុន្តែក្នុងករណីមានរយៈពេលលើសពី០១ខែឡើងទៅ ត្រូវមានលិខិតប្រគល់សិទ្ធិច្បាស់លាស់ ។

**ប្រការ៥ :**

ការិយាល័យនិមួយៗ ក្រោមឱវាទលេខាធិការដ្ឋានក្រុមប្រឹក្សា ត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូប អមដោយអនុប្រធានការិយាល័យមួយឬច្រើនរូប ដែលសុទ្ធតែត្រូវជ្រើសរើសចេញពីក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយមានឋានៈរៀងគ្នាស្មើនឹងប្រធាននិងអនុប្រធានការិយាល័យនៃក្របខ័ណ្ឌនេះ អោយជួយធ្វើការតាមការចាំបាច់ ។

ថ្នាក់ដឹកនាំការិយាល័យនិមួយៗ ត្រូវតែងតាំងឬផ្លាស់ប្តូរដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ ក.ជ.គ. ក្រោយពីបានពិគ្រោះយោបល់ដោយសម្លេងភាគច្រើន ។

**ប្រការ៦ :**

ដើម្បីទ្រទ្រង់ដំណើរការប្រកបដោយចីរភាពរបស់លេខាធិការដ្ឋានក្រុមប្រឹក្សា ក.ជ.គ.ត្រូវបានអនុញ្ញាត អោយមាន ក្រៅពីមន្ត្រីដឹកនាំដែលចែងក្នុងប្រការ៤និង៥ខាងលើ នូវកម្លាំងបន្ថែមអោយបំរើការនៅក្នុងលេខាធិការដ្ឋាន ក្រុមប្រឹក្សា តាមរយៈ :

១- ការស្នើសុំបុគ្គលិកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរូបភាពព្យួរក្របខ័ណ្ឌនិងប្រាក់បៀវត្ស និង/ឬ

២- ការជ្រើសរើសបុគ្គលិកពីខាងក្រៅ ដោយជាប់កិច្ចសន្យា ក្រោយពីមានការឯកភាពជាមុនពីក្រសួង អាណាព្យាបាលនេះ ។

**ប្រការ៧ :**

លាភការក៏ដូចប្រាក់បៀវត្សនិងអត្ថប្រយោជន៍ផ្សេងៗសំរាប់មន្ត្រី-បុគ្គលិកបំរើការគ្រប់លំដាប់ថ្នាក់ នៅក្នុង លេខាធិការដ្ឋានក្រុមប្រឹក្សា រាប់បញ្ចូលទាំងសមាសភាពក្នុងគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍ និង/ឬ អនុគណៈ-កម្មការបច្ចេកទេសដែលចែងនៅប្រការ៣ខាងលើផងដែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ តាមសំណើរបស់ក.ជ.គ. និងត្រូវចំណាយដោយថវិកាផ្ទាល់របស់ក.ជ.គ. ដែលចែងនៅមាត្រា១៤ នៃអនុក្រឹត្យ ដែលយោងនៅប្រការ១ នៃប្រកាសនេះ។

**ប្រការ៨ :**

លេខាធិការដ្ឋានក្រុមប្រឹក្សាត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដងក្នុងមួយខែ តាមការកោះអញ្ជើញនិង នៅក្រោមអធិបតីភាពរបស់ប្រធានក.ជ.គ. ។ ប៉ុន្តែក្នុងករណីចាំបាច់ ប្រធាន ក.ជ.គ.អាចចាត់តាំងលេខាធិការនៃ លេខាធិការដ្ឋានក្រុមប្រឹក្សា អោយបំពេញកិច្ចការនេះជំនួសបាន ។

**ប្រការ៩ :**

ដើម្បីធានាលំហូរការងាររលូនរបស់ខ្លួន លេខាធិការដ្ឋានក្រុមប្រឹក្សាត្រូវបានអនុញ្ញាតអោយប្រើប្រាស់ត្រា របស់ ក.ជ.គ. ប៉ុន្តែនៅក្រោមការទទួលខុសត្រូវនិងការប្រុងប្រយ័ត្នខ្ពស់ ។

## ជំពូកទី៣

## អំពីមុខងារ-ភារកិច្ចរបស់លេខាធិការដ្ឋានក្រុមប្រឹក្សានិងរបស់ការិយាល័យក្រោមឱវាទ

**ប្រការ១០ :**

មុខងារ-ភារកិច្ចរបស់លេខាធិការដ្ឋានក្រុមប្រឹក្សា គឺទទួលបន្ទុកគ្រប់គ្រងរដ្ឋបាលទូទៅនិងតាមដានការងារ បច្ចេកទេសរបស់ក.ជ.គ.ស្របទៅតាមមាត្រា៧នៃច្បាប់ស្តីពីគណនេយ្យសវនកម្ម សវនកម្មគណនេយ្យសហគ្រាស

និងវិជ្ជាជីវៈគណនេយ្យ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នសម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០២ និងតាមមាត្រា២ នៃអនុក្រឹត្យ ដូចមានយោងនៅប្រការ១ខាងលើ ដែលបានចែងក្នុងន័យថា ក្រុមប្រឹក្សាជាតិគណនេយ្យត្រូវបានបង្កើតឡើង អោយនៅក្រោមអាណាព្យាបាលភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយមានភារកិច្ច :

-ធ្វើជាអង្គការពិគ្រោះយោបល់

-ពិនិត្យនិងផ្តល់យោបល់លើរាល់គំរោងច្បាប់និងបទបញ្ញានានាដែលមានបទប្បញ្ញត្តិទាក់ទងទៅនឹងការរៀបចំកិច្ចការគណនេយ្យ សំរាប់រាល់សហគ្រាសឬសកម្មភាពសេដ្ឋកិច្ច

-រៀបចំក្របខ័ណ្ឌទស្សនាទាននិងស្តង់ដារគណនេយ្យ ដូចមានចែងនៅក្នុងមាត្រា៤នៃច្បាប់នេះ

-ស្នើឡើងនូវមធ្យោបាយសម្រាប់កែលំអបច្ចេកទេសគណនេយ្យ

-ធ្វើជាតំណាងព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការអន្តរជាតិ និងនៅក្នុងកិច្ចប្រជុំដើម្បីជជែកវែកញែកអំពីគណនេយ្យ ។

ផ្តើមចេញពីភារកិច្ចរបស់ក.ជ.គ. ដែលកំណត់ដោយច្បាប់និងអនុក្រឹត្យដូចខាងលើមុខងារភារកិច្ចជាក់ស្តែងរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាត្រូវបានកំណត់ដូចខាងក្រោម :

១- រៀបចំកម្មវិធីការងារជូនថ្នាក់ដឹកនាំ ក.ជ.គ. និងកំណត់ហេតុឬរបាយការណ៍នៃរាល់អង្គប្រជុំ

២- ការចូលរួមរបស់លេខាធិការ ក្នុងរាល់អង្គប្រជុំក.ជ.គ. ប៉ុន្តែដោយគ្មានសម្លេងសំរេចទេ

៣- ការសំរបសំរួលកិច្ចសហការរវាងលេខាធិការដ្ឋានក្រុមប្រឹក្សានិងគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍ និង/ឬអនុគណៈកម្មការបច្ចេកទេសដែលត្រូវបង្កើតឡើងតាមសេចក្តីសំរេចរបស់ក.ជ.គ.

៤- ការគ្រប់គ្រងរដ្ឋបាលទូទៅនិងទ្រព្យសម្បត្តិរបស់ក.ជ.គ.

៥- ការរៀបចំខ្លឹមសារនៃការពិគ្រោះយោបល់របស់ថ្នាក់ដឹកនាំក.ជ.គ. ជាមួយស្ថាប័នឬអង្គការជាតិនិងអន្តរជាតិដែលពាក់ព័ន្ធនានា តាមកម្មវិធីជាក់ស្តែង

៦- ការរៀបចំឬការពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក.ជ.គ. លើរាល់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានផ្សេងទៀត ដែលពាក់ព័ន្ធឬប៉ះពាល់ដល់ការគ្រប់គ្រងគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាសនិងវិជ្ជាជីវៈគណនេយ្យនៅកម្ពុជា ការតាមដានការអនុវត្តន៍និងការធ្វើរបាយការណ៍ជូនក.ជ.គ.ពីភាពមិនប្រក្រតី ដោយសហការជាមួយគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍

៧- ការរៀបចំរបាយការណ៍សរុបលទ្ធផលសកម្មភាពប្រចាំគ្រប់គ្រាកំណត់ឬសកម្មភាពកើតឡើងជាយថាហេតុរបស់លេខាធិការដ្ឋានខ្លួនឯង ជូនប្រធានក.ជ.គ. និងរបស់ក.ជ.គ. ជូនទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៨- ការលើកសំណើជូនថ្នាក់ដឹកនាំក.ជ.គ. ដើម្បីពិនិត្យនិងសំរេចលើការជ្រើសរើស-ការតែងតាំង-ការបញ្ចុះឋានៈឬការដកចេញពីតំណែង ឬវិធានការរដ្ឋបាលដោយប្រការណាមួយ ចំពោះមន្ត្រី-បុគ្គលិកនៅក្រោមឱវាទ

៩- ការទទួលបណ្តឹងតវ៉ាផ្សេងៗ ហើយសិក្សានិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក.ជ.គ. ដើម្បីសំរេចវិធានការសមស្រប និង

១០-ការអនុវត្តន៏អោយបានសំរេចនូវរាល់កិច្ចការផ្សេងៗទៀត ដែលប្រធានក.ជ.គ. ប្រគល់ជូន ។

**ប្រការ១១ :**

ការិយាល័យរដ្ឋបាលនិងទំនាក់ទំនងសាធារណៈ បំពេញតួនាទីជាអង្គភាពអនុវត្តផ្ទាល់ ចំពោះផែនការងារដែលមានចរិតរដ្ឋបាល ក្រោមការគ្រប់គ្រងរបស់លេខាធិការ រួមមានមុខងារ-ភារកិច្ចចំបងៗ ក្នុង :

១- ការរៀបចំកម្មវិធីនិងលំហូរការងារសំរាប់ថ្នាក់ដឹកនាំលេខាធិការដ្ឋាននិងក.ជ.គ. ក៏ដូចគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍និង/ឬអនុគណៈកម្មការបច្ចេកទេស

២- ការរ៉ាប់រងចំពោះការរៀបចំ លំហូរចេញ-ចូលនៃលិខិតស្នាមរដ្ឋបាលនិងបច្ចេកទេសគ្រប់ប្រភេទ ក្នុងទំនាក់-ទំនងជាមួយស្ថាប័នរដ្ឋ អង្គការជាតិនិងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគ្រាសនិងក្រុមហ៊ុននានា និងការបែងចែកនិងការរក្សាទុកដាក់គង់វង្សល្អក្នុងពេលកំណត់នៃច្បាប់ ចំពោះឯកសារទាំងនោះ

៣- ការគោរពបទបញ្ជាផ្ទៃក្នុង ការរក្សាអនាម័យ សោភណ្ឌភាព សណ្តាប់ធ្នាប់ សន្តិសុខនិងសុវត្ថិភាព ចំពោះទីកន្លែងធ្វើការ របស់ក.ជ.គ

៤- កិច្ចការពិធីការ រួមមាន បដិសណ្ឋារកិច្ច ការស្នាក់អាស្រ័យនៅ ការជូនដំណើរទស្សនកិច្ចនិងមាតុភូមិនិវត្តន៏ ចំពោះភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងការប្រារព្ធពិធីផ្សេងៗ របស់ក.ជ.គ. តាមការជាក់ស្តែង

៥- ការដោះស្រាយលិខិតស្នាម សោហ៊ុយឬមធ្យោបាយធ្វើបេសកកម្មទាំងក្នុងទាំងក្រៅប្រទេស សំរាប់មន្ត្រី-បុគ្គលិកគ្រប់លំដាប់នៃក.ជ.គ ដោយសហការជិតស្និទ្ធជាមួយការិយាល័យគណនេយ្យនិង ហិរញ្ញវត្ថុ

៦- ការរៀបចំខ្លឹមសារនៃការពិគ្រោះយោបល់របស់ថ្នាក់ដឹកនាំក.ជ.គ. ជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងសន្និសិទ សិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលបច្ចេកទេស ដោយសហការជិតជិតស្និទ្ធជាមួយការិយាល័យបញ្ញត្តិកម្មនិងត្រួតពិនិត្យ

៧- ការកសាងគំរោងចំណាយទ្រទ្រង់ក.ជ.គប្រចាំឆ្នាំនិមួយៗ និងការអនុវត្តន៏ចំណាយជាក់ស្តែង ប្រកបដោយតម្លាភាពនិងគណនេយ្យភាព ដោយសហការជិតស្និទ្ធជាមួយការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ

៨- ការដោះស្រាយប្រាក់បៀវត្សនិងអត្ថប្រយោជន៏ផ្សេងៗជូនមន្ត្រី-បុគ្គលិកទាំងអស់នៃក.ជ.គ. រាប់បញ្ចូលទាំងតំណាងស្ថាប័នដែលចូលរួមប្រជុំ ឬគ្រូបណ្តុះបណ្តាលទាំងឡាយ ទៅតាមរបបកំណត់

៩- ការលើកសំណើធ្វើលទ្ធកម្មចូលឬការលក់បញ្ចេញចោល នូវទ្រព្យសម្បត្តិជាមធ្យោបាយធ្វើការនិងសំភារៈផ្គត់ផ្គង់គ្រប់ប្រភេទ និងការថែទាំជួសជុលព្រមទាំងការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌច្បាស់លាស់ត្រឹមត្រូវនិងគង់វង្សល្អ

១០-ការរៀបចំរបាយការណ៍ប្រចាំគ្រាកំណត់ឬជាយថាហេតុរបស់លេខាធិការដ្ឋាន ជូនថ្នាក់ដឹកនាំក.ជ.គ. និង របស់ក.ជ.គ.ជូនទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាប់បញ្ចូលទាំងការទទួលបណ្តឹងតវ៉ាគ្រប់ប្រភេទ ដើម្បីជូនទៅការិយាល័យបញ្ញត្តិកម្មនិងត្រួតពិនិត្យចាត់ការបន្ត និង

១១-ការអនុវត្តន៍អោយបានសំរេចនូវរាល់កិច្ចការផ្សេងៗទៀត ដែលលេខាធិការ ប្រគល់ជូន ។

**ប្រការ១២ :**

ការិយាល័យបញ្ញត្តិកម្មនិងត្រួតពិនិត្យបំពេញតួនាទីជាអង្គភាពអនុវត្តផ្ទាល់ ចំពោះផែនការងារដែលមានចរិតជាបទបញ្ញាបច្ចេកទេស នៅក្រោមការណែនាំរបស់លេខាធិការ រួមមានមុខងារ-ភារកិច្ចចំបងៗ ដូច ខាងក្រោម :

១- ការសំរបសំរួលកិច្ចសហការល្អជាមួយការិយាល័យដទៃ និងជាមួយគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍ និង/ឬ អនុគណៈកម្មការបច្ចេកទេស ដើម្បីបុព្វហេតុភារកិច្ចរួមរបស់ក.ជ.គ.

២- ការសិក្សានិងផ្តល់យោបល់លើរាល់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានផ្សេងៗ ដើម្បីបញ្ចៀសវាទប្បដិវាទជាមួយច្បាប់ អនុក្រឹត្យ ប្រកាស បទបញ្ញា ស្តង់ដារនិងលិខិតបទដ្ឋាននានាជាធរមាន ស្តីពីការគ្រប់គ្រងគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក.ជ.គ.

៣- ការសិក្សានិងការរៀបចំរាល់ប្រកាស បទបញ្ញា ស្តង់ដារ សេចក្តីណែនាំ សារាចរ សេចក្តីជូនដំណឹង បច្ចេកទេសថ្មីៗ ដែលចាំបាច់ដាក់ចេញអោយអនុវត្ត ជុំវិញគណនេយ្យសហគ្រាស សវនកម្មគណនេយ្យ សហគ្រាស និង វិជ្ជាជីវៈគណនេយ្យ និងការតាមដានទៅតាមនីតិវិធីឬលក្ខខ័ណ្ឌកំណត់អោយមានការអនុវត្តន៍ត្រឹមត្រូវ នៅគ្រប់មជ្ឈដ្ឋានសហគ្រាសឬក្រុមហ៊ុន គណនេយ្យករជំនាញនិងសវនករប្រតិស្រុត ដោយមានកិច្ចសហការជាមួយគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍

៤- ការរៀបចំរបាយការណ៍បច្ចេកទេសជូនក.ជ.គ. ពីភាពមិនប្រក្រតី ដែលត្រួតពិនិត្យឃើញ និងរបាយការណ៍បច្ចេកទេសរបស់ក.ជ.គ. ជូនទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចាំបាច់

៥- ការចូលរួមសង្កេតការណ៍នៅក្នុងវិស័យសវនកម្មរបស់គណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍ លើសហគ្រាស ក្រុមហ៊ុនគណនេយ្យករជំនាញ ឬសវនករប្រតិស្រុត ទៅតាមសេចក្តីសំរេចរបស់ក.ជ.គ. និងការទទួលរបាយការណ៍សវនកម្មនេះពីគណៈកម្មការបច្ចេកទេសអចិន្ត្រៃយ៍ ជូនទៅប្រធានក.ជ.គ.ចាត់វិធានការតាមការជាក់ស្តែង

៦- ការសិក្សានិងផ្តល់យោបល់លើបណ្តឹងតវ៉ាផ្សេងៗ ដែលបញ្ជូនមកពីការិយាល័យរដ្ឋបាលនិងទំនាក់ទំនងសាធារណៈ ជូនទៅប្រធានក.ជ.គ. ដើម្បីសំរេចវិធានការទៅតាមករណីនីមួយៗ

៧- ការសិក្សាលើកគំរោងបណ្តុះបណ្តាលផ្នែកបច្ចេកទេស ជុំវិញគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដោយសហការជិតស្និទ្ធជាមួយការិយាល័យរដ្ឋបាលនិងទំនាក់ទំនងសាធារណៈ និង

៨- ការអនុវត្តន៏អោយបានសំរេចនូវរាល់កិច្ចការផ្សេងៗទៀត ដែលលេខាធិការប្រគល់ជូន ។

**ប្រការ១៣ :**

ការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុបំពេញតួនាទីជាអង្គភាពអនុវត្តផ្ទាល់ ចំពោះផែនការងារដែលពាក់ព័ន្ធដល់ការស្វែងរកនិងការគ្រប់គ្រងថវិការបស់ក.ជ.គ. រួមមានមុខងារ-ភារកិច្ចចំបងៗដូចតទៅ :

១- ការសិក្សានិងលើកសំណើដាក់ចេញនូវនីតិវិធីនិងគំរូសក្ខីប័ត្រជាក់ស្តែង ដើម្បីធានាគណនេយ្យភាព និងតម្លាភាព ចំពោះរាល់លំហូរចូលក៏ដូចលំហូរចេញនៃថវិការបស់ក.ជ.គ.

២- ការសិក្សានិងការកសាងគំរោងចំណូល-ចំណាយថវិកា ដោយបែងចែកតាមគ្រាកំណត់( ប្រចាំខែ-ត្រីមាស-ឆមាស-ឆ្នាំ) របស់ក.ជ.គ. ដោយសហការជិតស្និទ្ធជាមួយការិយាល័យដទៃៗទៀត

៣- ការកាន់កាប់គណនីនិងការកត់ត្រាតាមដានប្រចាំថ្ងៃ ចំពោះការអនុវត្តន៏ចំណាយថវិកា និងចំណូលថវិកាផ្អែកលើសក្ខីប័ត្រផ្តល់មកពីការិយាល័យនានា រាប់បញ្ចូលទាំងការធ្វើរបាយការណ៏ប្រចាំគ្រាកំណត់និមួយៗជូនប្រធានក.ជ.គ.

៤- ការគ្រប់គ្រងហ្មត់ចត់ចំពោះគណនីប្រាក់បញ្ញើផ្សេងៗ របស់ក.ជ.គ. នៅធនាគារមួយឬច្រើន នៅក្នុងប្រទេសដោយអនុលោមតាមគោលការណ៏គ្រឹះដែលកំណត់ឡើងសំរាប់កិច្ចការនេះ និងការធ្វើរបាយការណ៏ជូនប្រធានក.ជ.គ. តាមតម្រូវការជាក់ស្តែង

៥- ការត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌ ជាមួយអត្ថិភាពជាក់ស្តែងនៃចលនៈនិងអចលនទ្រព្យនានារបស់ក.ជ.គ. នៅដំណាច់ឆមាស និង/ឬដំណាច់ឆ្នាំនិមួយៗ ហើយធ្វើរបាយការណ៏តាមលទ្ធផលជាក់ស្តែង ដោយសហការជិតស្និទ្ធជាមួយការិយាល័យដទៃៗទៀត

៦- ការតាមដាន ការណែនាំកែតម្រូវ ចំពោះភាពមិនប្រក្រតីដែលពិនិត្យឃើញជាយថាហេតុ និង

៧- ការអនុវត្តអោយបានសំរេចនូវកិច្ចការផ្សេងទៀត ដែលលេខាធិការប្រគល់ជូន ។

## ជំពូកទី៤

## អំពីអវសានបញ្ញត្តិ

**ប្រការ១៤ :**

ក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន និងគ្រប់នាយកដ្ឋាន-អង្គភាព ក្រោមឱវាទ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ច រៀង១ខ្លួន។

**ប្រការ១៥** :

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល** :

-តាមប្រការ១៤

"ដើម្បីអនុវត្ត"

-កាលប្បវត្តិ-ឯកសារ

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាព័ត៌មាន "

-នាយកដ្ឋានរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧៥៧ សហវ.ប្រក.គស

រាជធានី ភ្នំពេញ, ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៦

## ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការ ទីស្នាក់ការគយនិងរដ្ឋាករ ប្រចាំឃ្លាំង និងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ តិច ស៊្រុន អ៊ីមផត អ៊ិចផត និងត្រេនស្ពត ( ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស៊្រុន )

*****

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ សេចក្តីជូនដំណឹងលេខ ១៦៣ សជណ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ ប្រកាសលេខ ០០៨ សហវ.គរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតការិយាល័យគ្រប់គ្រងផែស្ងួត និងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ✓

- យោងកិច្ចសន្យាស្តីពីការបង្កើត និងធ្វើអាជីវកម្មឃ្លាំងដែលគ្រប់គ្រងដោយគយ និងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ដែលផ្ទុកដោយកុងតឺន័រ រវាងទីចាត់ការគយនិងរដ្ឋាករ និងក្រុមហ៊ុនតិច ស្រ៊ុន អ៊ីមផត អិចស្ពត និង ត្រេនស្ពត ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦ ។
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១**: បង្កើត និងដាក់ឱ្យដំណើរការនូវ ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

**ប្រការ ២**: ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣**: ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រង និងត្រួតពិនិត្យទំនិញ ក្នុងទីតាំងផែស្ងួត លើគ្រប់ទំនិញនាំចេញក្រៅក្របខ័ណ្ឌវិនិយោគ និងទំនិញនាំចូលគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាតដោយឡែកពីទីចាត់ការគយនិងរដ្ឋាករ។
- ចាត់តាំងក្រុមអនុរក្ស និង ក្រុមត្រួតពិនិត្យ លើកិច្ចប្រតិបត្តិការគ្រប់គ្រងទំនិញ នាំចេញ នាំចូល ដែលស្ថិតនៅក្នុងឃ្លាំង និងទីលានបញ្ចេញទំនិញ ក្នុងផែស្ងួតតិច ស្រ៊ុន លើទំនិញដូចចែងខាងលើ ។
- ត្រួតពិនិត្យ និងប្រមូលពន្ធ ចំពោះមុខទំនិញ នាំចូល នាំចេញ ដូចចែងខាងលើ និងអនុញ្ញាតឱ្យទំនិញចេញពីឃ្លាំង និងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ក្រោយពីធ្វើការត្រួតពិនិត្យ និងបញ្ចប់បែបបទគយតាមបញ្ញត្តិច្បាប់ជាធរមាន ។

**ប្រការ ៤**: ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥**: ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**គាត ឈន់**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  « ដើម្បីជូនជ្រាប »
- ដូចប្រការ ៥ « ដើម្បីអនុវត្ត »
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០១១ សហវ.

# សារាចរណែនាំ

# ស្តីពីការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៦

យោងមាត្រា ១២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និងប្រការ ៣២ ប្រការ ៣៣ នៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ បានកំណត់ថា ថវិកាខេត្ត ក្រុងត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដូច្នេះ ដើម្បីធានាអោយការបិទបញ្ជីចំណូល ចំណាយ និងធ្វើរបាយការណ៍បូកសរុបទូទាត់ថវិកាខេត្ត ក្រុងប្រចាំឆ្នាំ ២០០៦ ប្រព្រឹត្តទៅបានត្រឹមត្រូវ និងទាន់ពេលវេលានោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសដូចតទៅ÷

១. អភិបាលខេត្ត ក្រុងដែលជាអាណាប័កដើមខ្សែ ត្រូវខិតខំជំរុញចំណូលសារពើពន្ធ និងប្រមូលចំណូលមិនមែនសារពើពន្ធ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន បង់ចូលថវិកាខេត្ត ក្រុងទាំងអស់យ៉ាងយូរត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។ ប្រសិនបើមានកាយឺតយ៉ាវក្រោយថ្ងៃកំណត់នេះ រតនាគារខេត្ត ក្រុង ត្រូវកត់ត្រាចូលជាចំណូលថវិកាខេត្ត ក្រុងសំរាប់ឆ្នាំ ២០០៧ ។

២. ការស្នើសុំថវិកាឧបត្ថម្ភតុល្យភាព ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ ។

៣. ការធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូក ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៦ ។ ដោយឡែកការធ្វើនិយ័តភាពឥណទានដែលពាក់ព័ន្ធដល់ការសុំអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងទាំងអស់ត្រូវបញ្ជូនសំណុំលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យ៉ាងយូរត្រឹមថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦ ។

វលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣ ៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

៤. រតនាគារខេត្ត ក្រុង ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់នៅម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។ ដូច្នេះក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវរួសរាន់ប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការ ដើម្បីធ្វើអាណត្តិ (ទាំងអាណត្តិទូទាត់ត្រង់ ទាំងអាណត្តិទូទាត់រជ្ជទេយ្យបុរេប្រទាន) បញ្ជូនទៅផ្នែកទិដ្ឋាការមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចដាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុងចុះហត្ថលេខា និងបញ្ជូនទៅរតនាគារខេត្ត ក្រុងអោយបានមុនម៉ោង ១៧ និង៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។

៥. នៅចុងថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ រតនាគារខេត្ត ក្រុង ត្រូវដំណើរការផ្ទេរសមតុល្យគណនីចំណូល ចំណាយរបស់សាលាខេត្ត ក្រុង ចូលទៅក្នុងគណនីលទ្ធផលនៃការិយបរិច្ឆេទ ។ ប្រសិនបើមានអតិរេកនោះសាលាខេត្ត ក្រុងត្រូវធ្វើសលាកប័ត្រចំណូលបង់ចូលថវិការដ្ឋឆ្នាំ ២០០៦ ជាបន្ទាន់ ក្នុងករណីមានការយឺតយ៉ាវស្ថិតនៅចន្លោះពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧នោះ កាលបរិច្ឆេទនៃការបង់ក៏ត្រូវចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ដែរ។ ផ្ទុយទៅវិញប្រសិនបើហួសកាលកំណត់ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧ ហើយសាលាខេត្ត ក្រុង នៅតែពុំទាន់បានបង់ទេនោះ គឺរតនាគារខេត្ត ក្រុងត្រូវម្ចាស់ការផ្ទេរដោយស្វ័យប្រវត្តិចូលជាចំណូលថវិការដ្ឋ ហើយត្រូវជូនដំណឹងទៅសាលាខេត្ត ក្រុងអោយបានជ្រាប ។ កាលបរិច្ឆេទនៃការផ្ទេរនេះ ក៏ត្រូវចាត់ទុកថា ជាកិច្ចប្រតិបត្តិការថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ដែរ ។

៦. កិច្ចប្រតិបត្តិការនិយ័តភាវូបនីយកម្មរបស់រតនាគារ សំរាប់ថវិកាខេត្ត ក្រុង ឆ្នាំ ២០០៦ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ។ កិច្ចប្រតិបត្តិការនេះ ត្រូវបានពិនិត្យកត់ត្រាជាលេខនាបន្ថែមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលទាក់ទងទៅនឹង :

- ការកត់ត្រាជាស្ថាពរនៃចំណូល ឬនៃចំណាយ ដែលបានពិនិត្យកត់ត្រាជាលេខនាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
- អាណត្តិនិយ័តភាវូបនីយកម្ម ដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យបុរេប្រទានមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៦ ។
- ការកែប្រែលេខនាខុស ។

៧. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ រាល់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាខេត្ត ក្រុងឆ្នាំថ្មី ត្រូវកត់ត្រាចូលក្នុងគណនីថវិកាខេត្ត ក្រុងឆ្នាំ ២០០៧ ។

៨. ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ រតនាគារខេត្ត ក្រុង និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុង ត្រូវដំណើរការបូកសរុបនិងផ្ទៀងផ្ទាត់អំពីការអនុវត្តន៍ចំណូល ចំណាយថវិកា ខេត្ត ក្រុងឆ្នាំ ២០០៦ ដោយរតនាគារខេត្ត ក្រុងត្រូវបង្កើតតារាងតុល្យភាពគណនីប្រចាំឆ្នាំ និងក្រុមហិរញ្ញវត្ថុរបស់សាលាខេត្ត ក្រុងត្រូវធ្វើតារាង

បូកសរុបចំណូល ចំណាយថវិកាខេត្ត ក្រុងតាមមាតិកាថវិកា រួចធ្វើកំណត់បង្ហាញជាក់ជូនឯកឧត្តមអភិបាលខេត្ត ក្រុង ពិនិត្យសំរេច និងចុះហត្ថលេខា ។ អភិបាលខេត្ត ក្រុងត្រូវធ្វើលិខិតបញ្ជូនតារាងតុល្យភាពគណនីប្រចាំឆ្នាំតារាង បូកសរុបចំណូល ចំណាយ និងកំណត់បង្ហាញខាងលើទៅក្រសួងមហាផ្ទៃចំនួន ០១ច្បាប់ និងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ០២ច្បាប់ អោយបានមុនថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ដើម្បីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការបូកសរុប និងរៀបចំនូវរបាយការណ៍សំរេចទូទាត់ថវិកាខេត្ត ក្រុងរួមមួយ ដើម្បីដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

អភិបាលខេត្ត ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានតាមការកំណត់ដូចខាងលើ ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុប រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេច និងរដ្ឋសភា ព្រឹទ្ធសភាពិនិត្យអនុម័តអោយបានទាន់ពេលវេលា។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ធនាគារជាតិ
- សាលាខេត្ត ក្រុង
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង
- ធនាគារខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

លេខកូដ............

## តារាងបូកសរុបចំណូលថវិកាខេត្ត ក្រុង

## សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦

តារាងឧបសម្ព័ន្ធ១

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ<br>ចំណាត់ថ្នាក់ចំណូល | ច្បាប់<br>ហិរញ្ញវត្ថុដើមឆ្នាំ | អនុវត្ត<br>ជាក់ស្តែង | សមាមាត្រ<br>ប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤.៣ / ២ | |
| | | | | | | | | |
| | | | | សរុបរួម | | | | |

| | | | |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា |
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង.............

# តារាងបូកសរុបចំណាយថវិកាខេត្ត ក្រុង

លេខកូដ.............

# សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦

តារាងឧបសម្ព័ន្ធ២

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | បរិយាយ ចំណាត់ថ្នាក់ចំណាយ | ច្បាប់ ហិរញ្ញវត្ថុដើមឆ្នាំ | ឥណទាន អនុញ្ញាត | អនុវត្ត ជាក់ស្តែង | សមាមាត្រ ប្រៀបធៀប | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥-៤ / ៣ | |
| | | | | | | | | | |
| | | | | សរុបរួម | | | | | |

| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា |
|---|---|---|---|
| អភិបាលខេត្ត ក្រុង | ប្រធានរតនាគារខេត្ត ក្រុង | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អ្នកធ្វើតារាង |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៧៧ ពណ.នគក

ភ្នំពេញថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **សេរីបុត្រ អ៊ិនវេសមេន**
**SEREIBOTT INVESTMENTS Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9120/06P** ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **មុយ ម៉ុន**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១៣៦ BC ផ្លូវលេខ ៧០ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវារកយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦. ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៥២៥ ពណ.ឧតក

ភ្នំពេញថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គ្រេន ភ្នំពេញ ហ្គោល ខូ លីមីធីត**

GRAND PHNOM PENH GOLF CO., LTD.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9121/06P ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក BUDIARSA SASTRAWINATA " តតីយជន " ប្រធានក្រុមប្រឹក្សាភិបាល

លោក HARUN HAJADI " តតីយជន " អភិបាល

លោក CAKRA CIPUTRA " តតីយជន " អភិបាល

លោក CANDRA CIPUTRA " តតីយជន " អភិបាល

លោក AGUSSURJA WIDJAJA " តតីយជន " អភិបាល

លោកស្រី ម៉ៅ ម៉ាល័យ " តតីយជន " អភិបាល

លោក កែ សួនសុគា " តតីយជន " អភិបាល

លោក កែ សួនសុគាព " តតីយជន " អភិបាល

លោកស្រី កែ សួនសុភី " តតីយជន " អភិបាល

លោក ស សុខា " តតីយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ១.០០០ ដុល្លារអាមេរិក

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : - គំរោងវិនិយោគដែលទាក់ទងនឹងការអភិវឌ្ឍន៍ សាងសង់ ធ្វើជាកម្មសិទ្ធិ និងគ្រប់គ្រងលើទីលានវាយកូនហ្គោលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "បុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៥៧៦ ពណ.នគក

ភ្នំពេញ ថ្ងៃទី ០៥ ខែ ១១ ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **(ខេមបូឌា) គ្លូបិល ប៊ីស៊ីនីស ខូ អិលធីឌី**

**( CAMBODIA ) GLOBAL BUSINESS Co.,Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 3156/06E** ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៦

មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : អ្នកឧកញ៉ា **គិត ម៉េង** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ZE JIAN, CHEN** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៤៦ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ ឌីបរ៉ែក រាបរ៉ែពក់ទំនិញ នាំចូលឱសថ និង សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន -បោះពុម្ពផ្សាយ

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស-សេវាផ្សាយពាណិជ្ជកម្ម

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៣០ ពណ.នគក

ភ្នំពេញថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស វ៉ាយ អេស អ៊ីម៉ិច អេន ត្រេនស្ព័ត**

**S Y S IMEX AND TRANSPORT Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9133/06P ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ជុំ សារ៉េត** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **អ៊ុំ សុផាន់ណារ៉ា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៦ ផ្លូវលេខ ៦១៤ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -ស្តុកបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

- សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ជ. ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម សុីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២៥៣៦ ពណ.នតក

ភ្នំពេញថ្ងៃទី ០៦ ខែតុលា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : **ស៊ុន ចេង អ៊ីមផត អិចផត**
**SHUN CHENG IMPORT EXPORT Co., Ltd**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3163/06E ចុះថ្ងៃទី 04 ខែ តុលា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត
២- អភិបាលក្រុមហ៊ុន : លោក **YAO AIPIN**
៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ 63AEo ផ្លូវលេខ 450 សង្កាត់ទួលទំពូង 2 ខណ្ឌចំការមន រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការដួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការដូសដុលសំភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ចូននិងរំដោះគយទំនិញ
-សេវា យកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គីម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៧៥៣៤ ពណ.នតក

ភ្នំពេញថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេច.វី.ធី ខនស្រ្តាក់សិន**
**H. V. T CONSTRUCTION Co.,Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 9132/06P** ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ហេង ឧត្តី** ប្រធានក្រុមប្រឹក្សាភិបាល
លោកស្រី **កេត វ៉ាឌី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៤៥ ផ្លូវលេខ ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សាងសង់វីឡា ផ្ទះល្វែង អាគារខ្ពស់ៗ ជួសជុលអាគារ ស្ពាន ថ្នល់ កំពង់ផែ ព្រលានយន្តហោះសិក្សាគំរោងប្លង់ និងគូរប្លង់គ្រប់ប្រភេទ ចូលរួមដេញថ្លៃលើគំរោងសំណង់ និងម៉ៅការសាងសង់សំណង់ និងទទួលដេគ័រសំណង់គ្រប់ប្រភេទ
-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង អភិវឌ្ឍន៍ដីធ្លី ធ្វើអាជីវកម្មផ្សារ និងហាងទំនិញគ្រប់ប្រភេទ - ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ នាំចូលសំភារៈសំណង់គ្រប់ប្រភេទ ពីក្រៅប្រទេស និងក្នុងប្រទេស
-បើកសាលារៀនគ្រប់ប្រភេទ
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម និងបែបបទនៃការធ្វើវិនិយោគទុន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ បោះពុម្ពក្រដាសគ្រប់ប្រភេទ
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រផលិតដែក អំពូលភ្លើង ការ៉ូ កម្រាល ...

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

គឹម_ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ